លីកាដូ

LICADHO

សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

# កម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្សសំរាប់ព្រះសង្ឃ



# HUMAN RIGHTS EDUCATION PROGRAM FOR MONK

**សំរាប់អ្នកចូលរួម**

**FOR PARTICIPANTS**


រៀបចំដោយ

គ្រូអប់រំសិទ្ធិមនុស្សនៃអង្គការលីកាដូ

PREPARED BY

LICADHO'S TRAINERS

# កម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្សសំរាប់ព្រះសង្ឃ

## ១.បុព្វកថា :

ដោយយល់ឃើញថា ព្រះពុទ្ធសាសនាជាជំនឿយ៉ាងមុតមាំរបស់ពលរដ្ឋខ្មែរ ។ម្យ៉ាងវិញទៀតព្រះសង្ឃភាគច្រើនធ្លាប់បាននិមន្តចូលរួមសិក្សាស្វែងយល់អំពីសិទ្ធិមនុស្សនិងព្រះពុទ្ធសាសនារួចមកហើយ ដូច្នេះកម្មវិធីនេះចង់បង្កើនការយល់ដឹងថែមទៀតអំពីសិទ្ធិមនុស្ស ព្រមទាំងលើកឱ្យឃើញនូវបញ្ហាសិទ្ធិមនុស្សមួយចំនួនប្រគេនដល់ព្រះសង្ឃដើម្បីធ្វើការវិភាគ ។ ផងដែរ កម្មវិធីថ្មីនេះចង់បានការនិមន្តចូលរួមរបស់ព្រះសង្ឃឱ្យកាន់តែខ្លាំងក្លាឡើង ដើម្បីរួមចំណែកបង្កើតយុទ្ធសាស្ត្រទប់ស្កាត់អំពើរំលោភសិទ្ធិមនុស្សដែលបាននិងកំពុងតែកើតឡើង ហើយដែលបញ្ហាទាំងនោះនៅតែជាការលំបាកយ៉ាងធ្ងន់ធ្ងរ និង គំរាមកំហែងដល់ សន្តិសុខ និង ជីវភាពរស់នៅរបស់ប្រជា ពលរដ្ឋ រួមទាំងព្រះសង្ឃផងដែរ រហូតមកទល់ពេលនេះ ។

## ២.គោលបំណង នៅចុងបញ្ចប់នៃវគ្គ :

1-ព្រះសង្ឃនឹងយល់ស្របអំពីអ្វីដែលជាសំណូមពរសំរាប់ព្រះអង្គនៅក្នុងការពិភាក្សានេះ ដើម្បីរៀបចំបង្កើតយុទ្ធសាស្ត្រសំរាប់ការពារ។

2-ព្រះសង្ឃប្រាកដជាពេញព្រះទ័យនឹងបង្កើតជា " *ក្រុមសហការ* " ដែលជាយុទ្ធសាស្ត្រចម្បង សំរាប់ជួយអប់រំសិទ្ធិមនុស្សបន្តដល់ពុទ្ធបរិស័ទ និង ចូលរួមដោះស្រាយបញ្ហាអ្វីមួយតាមរយៈ "ក្រុម " តាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយសហការជាមួយក្រុមប្រជាពលរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលជាដើម ។

## ៣.វិធីដំណើរការនៃវគ្គ

កម្មវិធីសិក្សានៃវគ្គនេះទាំងមូល គឺជារបៀបពិភាក្សាផ្តល់យោបល់ឆ្លាទៅវិញទៅមក ក្នុងការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារសិទ្ធិមនុស្សនៅក្នុងមូលដ្ឋាន ។ ដូច្នេះបានន័យថាវគ្គនេះគឺផ្តល់ឱកាសឱ្យព្រះសង្ឃ ចូលរួមនិងផ្តល់យោបល់នៅក្នុងក្រុមពិភាក្សារបស់ព្រះអង្គទៅលើករណីសិក្សាជាច្រើន ថាតើគួររកដំណោះស្រាយបែបណា ដើម្បីជួយកាត់បន្ថយការរំលោភសិទ្ធិមនុស្សទាំងនោះឱ្យមានប្រសិទ្ធិភាព ។

★ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល០៣ថ្ងៃ នឹងរំពឹងទុកថា ព្រះសង្ឃទាំងអស់នឹងបញ្ចេញមតិយ៉ាងផុលផុសនិងពេញទំហឹងដើម្បីរកឱ្យឃើញនូវយុទ្ធសាស្ត្រសំរាប់ការពារ ។

★ វគ្គបណ្តុះបណ្តាលនេះ អ្នកសំរបសំរួលវគ្គនឹងមានរៀបចំល្បែងស្វាងគំនិត យ៉ាងហោចណាស់ក្នុងមួយថ្ងៃឱ្យបានមួយល្បែង។

★ នៅចុងបញ្ចប់នៃវគ្គ សិក្ខាកាមនឹងត្រូវបានស្នើសុំឱ្យធ្វើការវាយតំលៃទៅលើលទ្ធផលទូទៅរបស់វគ្គទាំងមូល។

★ បន្ទាប់ពីវគ្គនេះទៅ នឹងមានវគ្គបន្ត (Follow-up)ពីរដងទៀតដោយមានគម្លាតពីគ្នា ២ខែម្តងៗ វគ្គទាំងនោះគឺមានរយៈពេលតែ១ថ្ងៃ ប៉ុណ្ណោះ ។

# មាតិកា


| លេខរៀង | ឈ្មោះអត្ថបទ | ទំព័រ |
| --- | --- | --- |
| ១ | ★ព្រះពុទ្ធសាសនា និង សិទ្ធិមនុស្ស<br>1. ទស្សនៈ<br>2. សំណួរពិភាក្សានិងករណីសិក្សា<br>3. អត្ថបទជំនួយ | ១-៦ |
| ២ | ★តួនាទីព្រះសង្ឃទាក់ទងនឹងសិទ្ធិពលរដ្ឋនិងនយោបាយ<br>1. ទស្សនៈ<br>2. សំណួរពិភាក្សានិងករណីសិក្សា<br>3. អត្ថបទជំនួយ | ៧-១៣ |
| ៣ | ★ តួនាទីព្រះសង្ឃទាក់ទងទៅនឹងសិទ្ធិសេដ្ឋកិច្ច-សង្គមនិងវប្បធម៌<br>1. ទស្សនៈ<br>2. សំណួរពិភាក្សានិងករណីសិក្សា<br>3. អត្ថបទជំនួយ | ១៤-២០ |
| ៤ | ★លុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ<br>1.ទស្សនៈ<br>2.សំណួរពិភាក្សា<br>3.អត្ថបទជំនួយ : ទស្សនៈយេនឌ័រ | ២១-២៧ |
| ៥ | ★សិទ្ធិអប្បភាគជន<br>1.ទស្សនៈ<br>2.សំណួរពិភាក្សានិងករណីសិក្សា<br>3.អត្ថបទជំនួយ | ២៨-៣៤ |
| ៦ | ★ការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារ<br>1.ទស្សនៈ<br>2.ការៀបចំក្រុមស៊ីវិល<br>3.លំហាត់ពិភាក្សា<br>4.អត្ថបទជំនួយ | ៣៥-៤១ |

# ព្រះពុទ្ធសាសនា និង សិទ្ធិមនុស្ស

## I.ឧស្សនៈ

ព្រះពុទ្ធសាសនាបានហូរចូលមកក្នុងប្រទេសកម្ពុជា ប្រហែលជាក្នុងកំឡុងគ្រិស្តសករាជ ២០០ ទៅ ៦០០ ។ តែបើគិតពីអាយុកាលនៃកំណើតព្រះពុទ្ធសាសនាវិញ គឺមានជាង២៥សតវត្សមកហើយ ។

ព្រះពុទ្ធសាសនាត្រូវបានគោរពបូជាដោយប្រជាពលរដ្ឋខ្មែរប្រហែល ៩០ % ហេតុដូច្នេះហើយបានជាច្បាប់រដ្ឋធម្មនុញ្ញរបស់យើងបានចែងថា " ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ តែក៏មិនបដិសេធសិទ្ធិមានជំនឿចំពោះសាសនាដទៃដែរ " ។

ព្រះពុទ្ធសាសនាមានគោលការណ៍អប់រំមនុស្សយ៉ាងល្អប្រសើរបំផុត ដែលធ្វើឱ្យមនុស្សមានសុជីវធម៌ សីលធម៌ និងមានទ្រឹស្តីសព្វគ្រប់ដូចជា មាត្រាសេរីភាព ប្រជាធិបតេយ្យ សិទ្ធិមនុស្ស យុត្តិធម៌ វឌ្ឍនភាព ជាពិសេសផ្តោតទៅលើការបណ្តុះគំនិតឱ្យមានសន្តិភាពផ្លូវចិត្ត ឱ្យមានអហិង្សាធម៌ និងសេចក្តីស្ងប់ជាដើម ។

ចំពោះសិទ្ធិមនុស្សវិញ បើប្រៀបធៀបទៅនឹងលក្ខខណ្ឌធម្មជាតិ គឺមានតាំងពីការកកើតនៃមនុស្សគ្រប់ៗគ្នា ។ ដូច្នេះអ្វីដែលជួយសំរបសំរួលធ្វើឱ្យមនុស្សរស់នៅបានជាមួយគ្នា និងធ្វើឱ្យសង្គមមានវិន័យពីដំបូងឡើយនោះ គឺមានតែការអប់រំតាមរយៈសាសនាទាំងឡាយនេះឯង ។ ដូច្នេះអាចនិយាយបានថាសិទ្ធិមនុស្សមានមុនគេបង្អស់ ក៏ប៉ុន្តែអ្វីដែលចង់បង្ហាញនៅពេលនេះគឺចង់បញ្ជាក់អំពីខ្នាតគំរូសិទ្ធិមនុស្សមួយដែលបានរៀបចំតម្រូវតាមសិទ្ធិមនុស្សពីកំណើត ។ ខ្នាតគំរូសិទ្ធិមនុស្សនេះត្រូវបានប្រកាសឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីឆ្នាំ ១៩៤៨ ដោយបានពិនិត្យឃើញថា ទោះបីជាមានសាសនាអប់រំក៏ដោយ ក៏មនុស្សនៅតែកាប់សម្លាប់គ្នាឥតត្រាប្រណី ហើយនៅពេលខ្លះសាសនាត្រូវបានគេហាមប្រាមមិនឱ្យគោរព មានព្រះពុទ្ធសាសនាជាដើម ដូចជាប្រទេសកម្ពុជានៅប៉ុន្មានទសវត្សមុននេះ។

គោលការណ៍សិទ្ធិមនុស្ស បើប្រៀបធៀបទៅនឹងធម៌វិន័យព្រះពុទ្ធសាសនា មានមូលដ្ឋានទៅលើអរិយធម៌ ប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា សេរីភាព ប្រជាធិបតេយ្យ អភិវឌ្ឍន៍។ល។

ជាទូទៅគឺជាគោលការណ៍សន្តិភាពនិយម អហិង្សា ដូចជាទស្សនៈព្រះពុទ្ធសាសនាដែរ ក៏ប៉ុន្តែខ្លាត សិទ្ធិមនុស្សមានលក្ខណៈខ្ពីសាមញ្ញ សំរាប់លោកិយ ក្នុងការប្រព្រឹត្តរវាងគ្នានឹងគ្នាជាបងប្អូន មានសិទ្ធិស្មើៗគ្នា គោរពសេចក្តីថ្លៃថ្នូររបស់មនុស្សដោយគ្មានការរើសអើង ហើយបើសិនជាមាននរណាម្នាក់ត្រូវគេប្រព្រឹត្តមកលើ ដោយផ្តល់ឱ្យមានការឈឺចាប់ ដល់ផ្លូវចិត្តឬផ្លូវកាយ អ្នកដែលប្រព្រឹត្តនោះនឹងត្រូវទទួលទោសតាមផ្លូវច្បាប់ ។ ប៉ុន្តែកន្លងមកក៏មានព្រះសង្ឃខ្លះមិនរវីរវល់នឹង អំពើហិង្សា



ឡើយ ទោះជាព្រះអង្គបានជួបនឹងឧប្បត្តិហេតុដែលកើតឡើងក៏ដោយ ។ ម្យ៉ាងវិញទៀតនៅមានព្រះសង្ឃខ្លះរហូត ទៅដល់ប្រើអំពើហិង្សាដ៏ឃោរឃៅដោយផ្ទាល់ព្រះអង្គឯង ទៅលើគ្រហស្ថថែមទៀតផង ។

ដូច្នេះ ព្រះសង្ឃគួរតែប្រកាន់ឱ្យខ្ជាប់នូវធម៌វិន័យរបស់ព្រះពុទ្ធសាសនាក៏ដូចជាការគោរពសិទ្ធិមនុស្ស ហើយនិងយកសិទ្ធិមនុស្ស

***(ការសម្លាប់ដោយហ្វូងមនុស្ស ដែលមិនត្រូវឱ្យមានតទៅទៀត)***

ទៅអប់រំ-ផ្សព្វផ្សាយដល់ពុទ្ធបរិស័ទផងដែរ ដោយមិនគិតថាសិទ្ធិមនុស្សជារឿងរបស់មនុស្សលោក នាំឱ្យខូចដល់ធម៌វិន័យព្រះពុទ្ធសាសនានោះឡើយ ។




សន្តិភាព , អហិង្សា ,សុជីវធម៌ , សីលធម៌ ,ប្រពៃណី , វប្បធម៌
សេរីភាព , ប្រជាធិបតេយ្យ ,អភិវឌ្ឍន៍

## ១-សំណួរ

1-តើកន្លងមកព្រះតេជគុណបានចាប់អារម្មណ៍ និងយកព្រះទ័យទុកដាក់លើបញ្ហាសិទ្ធិមនុស្សទៅអប់រំដល់ពុទ្ធបរិស័ទដែរឬទេ ? បើមាន បានលើកយកចំណុចណាខ្លះ ? បើមិនបាន មកពីហេតុអ្វី ?

2-រវាងទស្សនៈសិទ្ធិមនុស្ស និងទស្សនៈព្រះពុទ្ធសាសនា តើមានចំណុចណាដែលត្រូវគ្នា សូមផ្តល់ឧទាហរណ៍តែ ៣-៤ ចំណុចប៉ុណ្ណោះ ? តើមានចំណុចណាដែលខុសគ្នាស្រឡះ សូមផ្តល់ឧទាហរណ៍តែ១-២ចំណុច ។

3-តើគួរជាការភ័យខ្លាចរបស់ព្រះសង្ឃ ឬក៏ខ្លាចខុសធម៌វិន័យព្រះពុទ្ធសាសនា ចំពោះព្រះសង្ឃខ្លះដែលបានយល់ដឹងពីសិទ្ធិមនុស្សហើយ តែមិនបានយកសិទ្ធិមនុស្សទៅអប់រំបន្តក្នុងចំណោមពុទ្ធបរិស័ទ ដូចជានៅពេលធម្មទេសនាជាដើម ?

## ២-ករណីសិក្សា :

**ទី១** : មានបុរសម្នាក់ ត្រូវបានចោមរោមវាយដោយហ្វូងមនុស្ស ដែលជាក្រុមសិស្សគណស្នាក់អាស្រ័យនៅក្នុងវត្ត បណ្តាលឱ្យបុរសនោះបែកក្បាល-ហូរឈាមរហូតដល់សន្លប់ពេញមួយយប់ ដោយសង្ស័យថាជាចោរ ។ ពេលកំពុងកើតហេតុនោះក៏មានការចោមរោមឈរមើលពីសំណាក់ព្រះសង្ឃជាច្រើនអង្គដែរ ព្រះសង្ឃខ្លះមានទឹកព្រះទ័យសប្បាយរីករាយដោយស្អប់ថាចោរ ព្រះសង្ឃខ្លះមិនមានសង្ឃដីកាអ្វីទេ និងឃើញមានមួយអង្គដែលអាណោចអធម្ម ។

**ទី២** : មានរឿងប្រហាក់ប្រហែលគ្នាដោយព្រះសង្ឃគង់នៅវត្តពីរផ្សេងគ្នា ។ ព្រះសង្ឃវត្តទី១បានបញ្ជាឱ្យអង្គរក្សរបស់ព្រះអង្គវាយមនុស្សដាច់សង្វែងម្នាក់ រាងឡប់ៗដែលសុំស្នាក់ក្នុងវត្ត និងសង្ស័យ

ថាបានលួចរបស់វត្ត ហើយត្រូវអង្គរក្សនោះវាយដល់សន្លប់ បន្ទាប់មកក៏យកទៅបោះចោលនៅក្បែរភូមិអ្នកស្រុក ។

ព្រះសង្ឃវត្តទី២ក៏បានបញ្ជាឱ្យអង្គរក្សឆ្វេងស្តាំរបស់លោក វាយកុមារម្នាក់នឹងដែកព្យួរខោអាវ ធ្វើឱ្យបែកហូរឈាមយ៉ាងខ្លាំងនៅលើខ្នង មូលហេតុដោយកុមារនោះបានលួចលុយព្រះអង្គ ។ តាមសាក្សីបានសន្និដ្ឋានថា ការវាយដំរហូតដល់ថ្នាក់នេះគឺជាអំពើទារុណកម្មមួយយ៉ាងឃោរឃៅ ។

**ទី៣ :** មានកុមារជំទង់ម្នាក់បានជិះកង់កិនទុយយោកំពុងបូមទឹករបស់លោកសង្ឃមួយអង្គ នៅក្នុងវត្តមួយ។ ពេលនោះព្រះសង្ឃអង្គនោះបានឃើញ ហើយពេលនោះដែរ កុមារនោះក៏ដើរចូលមកសុំអង្វរកពីកំហុសរបស់ខ្លួន តែព្រះសង្ឃអង្គនោះមិនទទួលការសុំទោសរបស់កុមារនោះឡើយ ផ្ទុយទៅវិញ ព្រះអង្គបានយកឈើច្រត់វាយកុមារនោះឡើងបែកក្បាលហូរឈាម ដោយសារតែការកិនទុយយោបូមទឹកនោះ ។ បន្ទាប់មកលោកបានបង់ជម្ងឺចិត្តឱ្យកុមារនោះ១លានរៀល ដើម្បីព្យាបាលជម្ងឺ ។

**★ការពិភាក្សាតាមក្រុម**

**+ សំនួរសំរាប់ក្រុមទី១ :**

1-តាមករណីសិក្សានេះបានបញ្ជាក់ថា មានព្រះសង្ឃចោមរោមមើលនៅពេលកើតឧប្បត្តិហេតុនោះ តើព្រះសង្ឃក្រុមមួយណាទៅដែលព្រះអង្គគាំទ្រ ? ហេតុអ្វី ?

2-តើព្រះអង្គមានយោបល់ឬមានដំណោះស្រាយ ឬមានវិធីចាត់ការដូចម្តេច បើសិនជាព្រះអង្គបានជួបឧប្បត្តិហេតុដែលបានកើតឡើងទៅលើជននោះ ?

**+ សំនួរសំរាប់ក្រុមទី២:**

1-យោងតាមករណីសិក្សាថា ព្រះសង្ឃទាំងពីរអង្គនោះមិនបានធ្វើអ្វីឱ្យប៉ះពាល់ដល់រូបរាងកាយជនសង្ស័យនោះដោយព្រះអង្គផ្ទាល់ទេ គឺជាអង្គរក្សរបស់ព្រះអង្គ ហើយទង្វើនេះសមនឹងជនសង្ស័យនោះត្រូវទទួលដើម្បីឱ្យគេរាងចាល ព្រោះឥឡូវកើតចោរលួច-ចោរប្លន់ច្រើនណាស់ ។ ត្រឹមត្រូវ ឬមិនត្រឹមត្រូវ ? ត្រឹមត្រូវត្រង់កន្លែងណា និងមិនត្រឹមត្រូវត្រង់កន្លែងណា សូមព្រះអង្គផ្តល់ព្រះពុទ្ធដីកា ។

2-តើទង្វើដែលបានប្រព្រឹត្តទៅលើជនរងគ្រោះនោះ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្សឬទេ ? បើមានតើប៉ះពាល់ដល់សិទ្ធិអ្វីខ្លះ ? បើសិនជាព្រះអង្គបានជួបឧប្បត្តិហេតុដូច្នេះវិញ តើព្រះអង្គគួរបានដោះស្រាយតាមវិធីដូចម្តេចខ្លះ ? សូមផ្តល់សង្ឃដីកា ។

**+ សំនួរក្រុមទី៣-៤ :**

1-យោងតាមករណីសិក្សាខាងលើ ព្រះសង្ឃអង្គនេះខ្វាល់ណាស់ ទប់ព្រះទ័យមិនទាន់ ព្រោះក្មេងនោះវាខ្វះការប្រុងប្រយ័ត្នធ្វើឱ្យខូចខាត ដូច្នេះត្រូវតែដោះស្រាយដោយវិធីនេះ ។ ម្យ៉ាងវិញទៀតព្រះសង្ឃ តាមទំនៀមទម្លាប់ខ្មែរលោកតែងមានឥទ្ធិពលទៅលើពុទ្ធបរិស័ទចំណុះជើងវត្ត ដូច្នេះវាយជ្រុលដៃប៉ុណ្ណេះក៏មិនអីដែរ ហើយលោកបានបង់ជម្ងឺចិត្តដល់ទៅមួយលានរៀលគឺជាការសមរម្យ ។ តើព្រះអង្គស្របនឹងយោបល់នេះទេ ? បើស្រប ហេតុអ្វី ? បើមិនស្រប ហេតុអ្វី ? សូមផ្តល់សង្ឃដីកា ។

2-តើរឿងនេះព្រះអង្គគួរដោះស្រាយដូចម្តេចវិញ ?

**៧-សំណួរ**

1-តើព្រះសង្ឃបានសិក្សាអំពីអ្វីខ្លះ អំបាញ់មិញនេះ ?

2-តើព្រះសង្ឃគួរមានវិធីដូចម្តេច ដើម្បីជួយកាត់បន្ថយអំពើរំលោភសិទ្ធិមនុស្សដែលកើតមានក្នុងសហគមន៍ ?

## II. អត្ថបទជំនួយ

### ១-សីល-វិន័យព្រះពុទ្ធសាសនា មានដូចជា

**បាណា** : ហាមសម្លាប់សត្វ ឬ

**សព្វេ សត្វា ភវន្តុ សុខិតត្តា**... 

**សុខកាមានិ ភូតានិ** : សព្វសត្វមានជីវិតតែងចង់បានសេចក្តីសុខ ឬ

**សព្វេសំ ជីវិតំ បិយំ** ( អានថា សាប់ពេសាំង ជីវិតាំង បិយ៉ាំង: ជីវិតជាទីស្រលាញ់សំរាប់សត្វមានជីវិត

★ **ព្រហ្មវិហារធម៌ :**

| | | |
|---|---|---|
| មេត្តា | : | សេចក្តីស្រលាញ់គ្មានព្រំដែន ប្រាថ្នាចង់ឱ្យអ្នកដទៃបានសេចក្តីសុខ |
| ករុណា | : | សេចក្តីអាណិតអាសូរ |
| មុទិតា | : | សេចក្តីត្រេកអរចំពោះអ្នកដទៃ |
| ឧបេក្ខា | : | ការដាក់ចិត្តជាកណ្តាល |

### ២-សិទ្ធិមនុស្ស

★ **សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស**

មាត្រា៣ : មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

មាត្រា៥ : គ្មានមនុស្សណាម្នាក់ត្រូវគេធ្វើទារុណកម្ម ឬប្រព្រឹត្តិកម្ម ឬក៏ដាក់ទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬថោកទាបបានទេ ។

**ចប់**

# តួនាទីព្រះសង្ឃទាក់ទងនឹងសិទ្ធិពលរដ្ឋនិងនយោបាយ

## I.ឧស្សនះ

សិទ្ធមនុស្សរួមមានសិទ្ធិពលរដ្ឋនិងនយោបាយ និង សិទ្ធិសេដ្ឋកិច្ច-សង្គម និងវប្បធម៌ ដែលត្រូវបានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងមានការទទួលស្គាល់និងគោរពដោយច្បាប់របស់ប្រទេសកម្ពុជាយ៉ាងជាក់លាក់ផងដែរ ។ ដូច្នេះមិនថាបព្វជិតឬគ្រហស្ថឡើយ គឺត្រូវទទួលបាននូវសិទ្ធិខាងលើនេះដូចៗគ្នា ។

ដោយឡែកព្រះសង្ឃបានតំណាងឱ្យព្រះពុទ្ធសាសនា ដែលជាទីគោរពសក្ការៈរបស់ប្រជាពលរដ្ឋខ្មែរប្រហែល ៩០% និងជាប្រពៃណីបានចាក់ឫសជ្រៅយូរលង់ណាស់មកហើយ ត្រង់ចំណុចនេះបើប្រៀបធៀបទៅនឹងសិទ្ធិពលរដ្ឋ និងនយោបាយគឺទាក់ទងទៅនឹងសិទ្ធិមានជំនឿសាសនា ។



សិទ្ធិពលរដ្ឋ និងនយោបាយ គឺជាខ្នាតសិទ្ធិមនុស្សមានចែងក្នុងច្បាប់ ហើយត្រូវបានប្រើប្រាស់ដោយពលរដ្ឋខ្មែរទូទៅក្នុងការបញ្ចេញសកម្មភាពអនុវត្តសិទ្ធិ សំរាប់ការកែលំអគំរិតជីវភាពរបស់ខ្លួន ឱ្យកាន់តែប្រសើរឡើង ។ បានន័យថា សិទ្ធិពលរដ្ឋ និង នយោបាយ ត្រូវបានបំរើឱ្យឬបំពេញឱ្យមនុស្សសំរាប់ការដោះស្រាយ ឬការទាមទារអ្វីមួយឱ្យមានតម្លាភាព-យុត្តិធម៌ ដែលជាកត្តានាំទៅរកការរីកចំរើនរបស់មនុស្ស និងសង្គមជាតិ ។

★<u>ឧទាហរណ៍</u> ខាងក្រោមនេះ ខ្លះជាវិជ្ជមាន (= ស្រប) និងខ្លះទៀតអវិជ្ជមាន មិនស្រប (≠) ។

-ព្រះសង្ឃទាមទារឱ្យក្រសួងធម្មការ គោរពសំណូមពររបស់វត្តអារ៉ាម

-ព្រះសង្ឃទាមទារការប្រលងឱ្យមានតម្លាភាព

-ព្រះសង្ឃដង្ហែរជាក្បួនទាមទារសន្តិភាព

-ព្រះសង្ឃមួយអង្គបានតវ៉ានៅមុខតុលាការ អំពីការបង្ខូចកេរ្តិ៍ឈ្មោះរបស់ព្រះអង្គពីរឿងស្រលាញ់ស្រី ។

-ព្រះសង្ឃមួយអង្គបានបោះឆ្នោតគាំទ្រគណបក្សនយោបាយមួយ

-ក្រុមគណបក្សនយោបាយមួយ ព្យាយាមកាច់បំបាក់ក្រុមគណបក្សនយោបាយមួយទៀត ។

-ប្រជាពលរដ្ឋម្នាក់ត្រូវគេតាមដានអំពី ការបញ្ចេញមតិរបស់គាត់ទៅលើការបោះឆ្នោតថ្នាក់ឃុំថាលទ្ធផលបោះឆ្នោតមិនសូវល្អ ។

-គ្រួសារមួយត្រូវគេលួងលោម-បញ្ឆោតយកកូនស្រីទៅធ្វើជាពេស្យាចារ

-ក្នុងភូមិនេះសម្បូរកើតអំពើហិង្សាគ្រួសារ ឬក៏ក្នុងភូមិនោះសម្បូរការទាស់ទែងវាយកាប់ចាក់គ្នា

-ព្រះសង្ឃមួយអង្គត្រូវគេវាយស្រាតស្បង់ចីពរពីការចូលរួមធ្វើបាតុកម្ម

-ប្រជាពលរដ្ឋរអ៊ូរទាំមិនហ៊ានតវ៉ានៅចំពោះមុខមេឃុំរបស់ខ្លួន ពីការទារយកពន្ធ ឬបង្ខិភាគទានផ្សេងៗ សំរាប់ចំណូលក្នុងឃុំ ដោយមិនមានគោលការណ៍ច្បាស់លាស់ ។

ឧទាហរណ៍ទាំងអស់ខាងលើនេះ មួយចំនួនបានបង្ហាញពីសិទ្ធិពលរដ្ឋនិងនយោបាយស្របច្បាប់ និង មួយចំនួនទៀតគឺជាការរំលោភទៅលើសិទ្ធិពលរដ្ឋនិងនយោបាយរបស់អ្នកដទៃ ដែលត្រូវតែបានកែប្រែដើម្បីជួយប្រជាពលរដ្ឋខ្មែរក្នុងគោលបំណងតែមួយគត់ អំពីការជួយការពារសិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់ក្នុងការរស់នៅរបស់ពួកគេឱ្យមានជីវភាពកាន់តែប្រសើរឡើង។

**១-សំនួរ**

1-តើការផ្តល់សិទ្ធិដូចខាងលើ វាធ្វើឱ្យប៉ះពាល់ដល់ធម៌-វិន័យព្រះពុទ្ធសាសនា ក្នុងឋានៈជាសង្ឃដែរឬទេ ? ហេតុអ្វី ?

2-ក្នុងចំណោមឧទាហរណ៍មួយចំនួនខាងលើ តើមានឧទាហរណ៍ណាខ្លះដែលបញ្ជាក់ពីការរំលោភសិទ្ធិពលរដ្ឋនិងនយោបាយ ?

3-តើកន្លងមកនៅក្នុងសហគមន៍របស់ព្រះអង្គមានការរំលោភទៅលើសិទ្ធិពលរដ្ឋ និង នយោបាយ ឬទេ ? ករណីអ្វីខ្លះ ? រំលោភដោយអ្នកណា ? អ្នកណាខ្លះត្រូវគេរំលោភ ?

4-តើមានព្រះសង្ឃត្រូវគេរំលោភដែរឬទេ ? អំពីមូលហេតុអ្វី ?

## ២-ករណីសិក្សា

ពូសេក និង មីងសំ ជាគ្រួសារមួយក្រីក្រ។ ក៏ប៉ុន្តែគ្រួសារនេះជាពុទ្ធសាសនិកដូចគ្រួសារដទៃឯទៀត នៅក្នុងភូមិដែរ ដែលតែងតែថ្វាយចង្ហាន់បិណ្ឌបាតមិនដែលសូវលោះ ។ ឥឡូវគ្រួសារនេះកំពុងមាន វិបត្តិជាទម្ងន់ ដោយកូនប្រុសរបស់គាត់កំពុងផ្ទុកជម្ងឺអេដស៍ និង កូនស្រីរបស់គាត់ដែលទើបនឹង ចេញពីផ្ទះជាមួយសាច់ញាតិម្នាក់នៅពេលថ្មីៗនេះ បានទទួលដំណឹងមកថា នាងត្រូវគេបោកយកទៅ លក់ក្នុងបនស្រីពេស្យា ។ ចំណែកពូសេកកំពុងត្រូវគេតាមដាន-យាយីអំពីសកម្មភាពរបស់គាត់ដែល កំពុងតែមានតួនាទីជាសកម្មជនរបស់គណបក្សមួយ ហើយកំពុងត្រូវបានគេចោទប្រកាន់ពីគណបក្ស នយោបាយមួយទៀតថា ពូសេកព្យាយាមបញ្ចុះបញ្ចូលអ្នកស្រុក ដើម្បីយកប្រជាប្រិយនិងយក ប្រៀបលើគណបក្សរបស់ពួកគេ ហើយបានបោះសំដីឱ្យពូសេកថា " ប្រយ័ត្នប្រពន្ធមេម៉ាយ " ។ ភាពកង្វល់របស់គ្រួសារនេះ មានអ្នកស្រុកខ្លះពេបជ្រាយថា ពូសេក និង មីងសំមិនចេះប្រដៅប្រដៅ កូន មិនចេះពិចារណាមុននឹងឱ្យកូនទៅជាមួយអ្នកដទៃ និងគាត់មិនគួរចូលរួមក្នុងរឿងនយោបាយ ធ្វើអ្វីទេ នាំឱ្យតែមានគ្រោះថ្នាក់ដល់ខ្លួន ។ រីឯអ្នកស្រុកខ្លះ អាណិតអាសូរគាត់និងគាំទ្រគាត់។ បន្ទាប់មកដំណឹងដ៏ក្រៀមក្រំរបស់គ្រួសារនេះត្រូវគេយកទៅនិយាយទូលដល់ព្រះ សង្ឃ។

★ សំណួរទាក់ទងនឹងករណីសិក្សាខាងលើ

1-តើគ្រួសាររបស់សេក មានកង្វល់ពីរឿងអ្វីខ្លះ ?

2-បើព្រះអង្គបានឮរឿងនេះហើយ តើព្រះអង្គមានព្រះទ័យដូចម្តេចចំពោះគ្រួសារនេះ ? ហេតុអ្វី ?

3-តើព្រះអង្គគួរស្តីបន្ទោស ឬមានវិធីនិងសកម្មភាពដូចម្តេច ទៅលើគ្រួសារនេះបើពួកគេជួបឧប-សគ្គធ្ងន់ធ្ងរដូច្នេះ ? បង្ហាញពីវិធី និង សកម្មភាព ។

4-តើមានតែគ្រួសារសេកមួយឬ ដែលមានឧបសគ្គដូច្នេះ ? ហេតុអ្វីទៅ ?

5-តើព្រះអង្គគួរមានវិធីណាខ្លះ  ដែលប្រសើរជាងគេសំរាប់ការប៉ះទង្គិចគ្នាចំពោះអ្នកគាំទ្រគណបក្សនយោបាយរៀង១ខ្លួន ហើយដែលពីមុនមកមានអ្នកបាត់បង់ជីវិតដោយសាររឿងនេះអស់ជាច្រើន ?

## II.អត្ថបទជំនួយ

### ១-បញ្ហាសិទ្ធិពលរដ្ឋនិងនយោបាយមួយចំនួន





| សិទ្ធិពលរដ្ឋ និង នយោបាយ |
|---|
| -សិទ្ធិរស់រានមានជីវិត |
| -សិទ្ធិគ្មានការរើសអើង |
| -សិទ្ធិមិនទទួលការចាប់ខ្លួន - ឃុំខ្លួនតាមអំពើចិត្ត |
| -សិទ្ធិខាងផ្លូវច្បាប់ |
| -សិទ្ធិឱ្យមានច្បាប់ការពារស្មើៗគ្នា |
| -សិទ្ធិមានការចូលរួមប្រជុំដោយសន្តិវិធី |
| -សិទ្ធិមិនទទួលរងការធ្វើទារុណកម្ម |
| -សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ |
| -សិទ្ធិបង្កើត និង ចូលរួមគណបក្សនយោបាយ |
| -សិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជន |
| -សិទ្ធិផ្តល់ពត៌មាន ទទួលពត៌មាន |
| -សិទ្ធិចូលរួមក្នុងរដ្ឋាភិបាល និងសង្គម |





## ២-ផ្លូវលោកនិងផ្លូវធម៌

ព្រះពុទ្ធសាសនា បានប្រៀនប្រដៅមនុស្សឱ្យប្រព្រឹត្តតែអំពើល្អ អំពើជាកុសល ចិត្តសន្តិភាព ។ល។ ក៏ប៉ុន្តែនៅក្នុងសង្គមនៃមនុស្សគឺតែងតែមានជនខិលខូចប្រព្រឹត្តអំពើអបាយមុខ ឬក៏ហ្វូងមនុស្សដែលមានទោសៈ មោហៈ លោភៈ រហូតដល់ជនទាំងនោះមានសកម្មភាពធ្វើឱ្យអ្នកដទៃមានការឈឺចាប់ដោយសារតែអំពើរបស់ខ្លួន ។

ការជួយមនុស្សមានវិធីសាស្ត្រច្រើនបែបច្រើនយ៉ាងណាស់ ចំណែកទិសដៅអប់រំ វាជាអាទិភាពមួយពិសេសមែនហើយសំរាប់លក្ខណៈយូរអង្វែង តែចំណុចខ្លះត្រូវមានការជួយជ្រោមជ្រែង ឬជួយរកវិធីដោះស្រាយឱ្យបានទាន់ពេល ដើម្បីជួយធ្វើឱ្យស្ថានភាពដែលអាក្រក់ទាំងឡាយនោះ បានធូរ

ស្រាល ឬ ចុះថយ ។ ឯការជួយមនុស្សនិងសង្គមដែលមានប្រសិទ្ធិភាពដែរនោះ គឺមិនមែនមានតែផ្លូវលោកមួយប៉ុណ្ណោះទេ គឺត្រូវមានផ្លូវធម៌ផងដែរ ទើបចលនានៃសង្គមរុងរឿងទៅបាន ។ ហេតុដូច្នេះហើយ ព្រះសង្ឃមានតួនាទីសំខាន់ណាស់សំរាប់ជួយតម្រង់សង្គមមនុស្សឱ្យកាន់តែបានល្អប្រសើរឡើង ។

**៣-ច្បាប់ជាក់ពន្ធ័ :**

**1-ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ អំពើលក់ដូរ និងអំពើអាជីវកម្មលើមនុស្ស**

**<u>មាត្រា៣ (ជំពូក ២)</u>**

ជនណាអូសទាញមនុស្ស ទោះស្រីឬប្រុស អនីតិជន ឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោម សន្យាឱ្យប្រាក់កាស ឬគ្រឿងអលង្ការ ឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខចិត្ត ឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំគំរាមកំហែង ឬប្រើថ្នាំសណ្តំស្មារតី និងសតិអារម្មណ៍ដើម្បីយកមកលក់ ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី១០ឆ្នាំដល់១៥ឆ្នាំ ។ បើជនរងគ្រោះជាអនីតិជនអាយុតិចជាង១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ឆ្នាំ ដល់ ២០ឆ្នាំ ។

អ្នកសមគំនិត អ្នកលក់ ឬអ្នកទទួលទិញ ឬអ្នកទទួលយក ត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ ។ ត្រូវចាត់ទុកជាអ្នកសមគំនិតដែរ អ្នកដែលបានផ្តល់ប្រាក់ ឬបានផ្តល់មធ្យោបាយផ្សេងៗសំរាប់បទល្មើស ។

មធ្យោបាយដឹកជញ្ជូនសំភារៈ និង ទ្រព្យសម្បត្តិប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

2-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

**<u>មាត្រា៣៥</u>** : ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានការទទួលពិនិត្យនិងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

**មាត្រា៤១:** ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភបំពាន នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

**មាត្រា៤២** : ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។ ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។




**-ឆន្ទាគតិ** : សេចក្តីលំអៀងព្រោះស្រលាញ់

**-ទោសាគតិ** : សេចក្តីលំអៀងព្រោះស្អប់

**-មោហាគតិ** : សេចក្តីលំអៀងព្រោះល្ងង់

**-ភយាគតិ** : សេចក្តីលំអៀងព្រោះខ្លាច

**★បាណា អទិន្នា កាមេ មុសា និងសុរា**

**ចប់**

# តួនាទីព្រះសង្ឃទាក់ទងទៅនឹងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

## I.ឧស្សុនៈ

សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌គឺជាសិទ្ធិមនុស្ស ហើយសិទ្ធិទាំងនេះ មិនមែនជាសេចក្តីត្រូវការសំរាប់តែគ្រហស្ថប៉ុណ្ណោះទេ តែវាជាសិទ្ធិចាំបាច់សំរាប់បព្វជិតផងដែរ ។ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ គឺជាលំអានសិទ្ធិពីកំណើតរបស់មនុស្ស ដូចជាត្រូវមានចំណីអាហារគ្រប់គ្រាន់ ការថែទាំសុខភាព សំលៀកបំពាក់ ទីជំរក ការមានតួស្រករ និងរៀបអាពាហ៍ពិពាហ៍ជាដើម ទាំងនេះជាតម្រូវការចាំបាច់របស់មនុស្សដែលមិនអាចខ្វះបានឡើយ ។



តាមប្រពៃណីតាំងពីបរមបុរាណមក ព្រះសង្ឃតែងតែបានចូលរួមចំណែកក្នុងការជួយដល់សហគមន៍ ដូចជាជួយកសាងផ្លូវ ស្ពាន សាលារៀន សាលាសំណាក់ និង វត្តអារាម ដែលជាទីកន្លែងសំរាប់គោរពសក្ការៈនិងជាពិសេស ជាថ្នាលបណ្តុះវិជ្ជាដល់កុលបុត្រខ្មែរគ្រប់ជំនាន់ អាចចាត់ទុកជាប្រភពធនធានមនុស្សតដូនតារៀងមក ។ ទន្ទឹមនឹងនេះដែរ

*(ព្រះសង្ឃផ្តល់ស្បៀងដល់ជនរងគ្រោះ)*

ព្រះសង្ឃអាចជាគ្រូពេទ្យដ៏ចំណាន ក្នុងការជួយព្យាបាលជម្ងឺដល់ពុទ្ធបរិស័ទផងដែរ ។ ទាំងអស់នេះហើយ គឺជាមោទនភាពនិងជាគុណូបការៈដ៏វិសេសវិសាលរបស់ព្រះពុទ្ធសាសនា ដែលមិនអាចបំភ្លេចបានឡើយ ។

ទ្រឹស្តីមួយបានលើកឡើងថា " ព្រះសង្ឃអាស្រ័យពុទ្ធបរិស័ទ " បានន័យថា បើពុទ្ធបរិស័ទមានព្រះសង្ឃក៏មាន បើពុទ្ធបរិស័ទក្រព្រះសង្ឃក៏ក្រ បើពុទ្ធបរិស័ទមានទុក្ខព្រះសង្ឃក៏មានទុក្ខ ។ល។

ដូច្នេះតាមការសង្កេតបច្ចុប្បន្ននេះ ប្រជាពលរដ្ឋខ្មែរភាគច្រើនលើសលប់កំពុងធ្លាក់ក្នុងសភាពក្រីក្រដុនដាប ដូចជា ខ្វះស្បៀង ខ្វះថ្នាំសង្កូវ ខ្វះជំរក ខ្វះគមនាគមន៍-សាលារៀន-មន្ទីរពេទ្យ-ខ្វះមធ្យោ

បាយផ្នែកកសិកម្ម នៅជនបទដាច់ស្រយាលកូនចៅមិនសូវចូលសាលា ចូលសិក្សាហើយរៀនមិនបានវែងឆ្ងាយព្រោះខ្វះថវិកា។ល។ ទន្ទឹមនឹងភាពក្រីក្រនេះផងដែរ មានប្រជាពលរដ្ឋនៅតំបន់ខ្លះកំពុងតែប្រឈមមុខនឹងបញ្ហារឹបអូសដីធ្លី ផ្ទះសម្បែង សម្បត្តិធម្មជាតិខ្លះៗមាននៅក្នុងភូមិ-ឃុំរបស់គេ ហើយដែលពីមុនមកគេមានសិទ្ធិស្នាក់អាស្រ័យនិងពឹងពាក់ទៅលើកម្មសិទ្ធិទាំងអស់នោះសំរាប់ជួយសំរួលជីវភាពរស់នៅរបស់ពួកគេ។

ការរៀបរាប់បង្ហាញឱ្យឃើញអំពីទុក្ខលំបាកនានាខាងលើនេះ មិនមែនមានបំណងបញ្ចុះបញ្ចូលប្រជាពលរដ្ឋឱ្យងាកចេញពីគន្លងព្រះពុទ្ធសាសនានោះទេ ហើយប្រជាពលរដ្ឋខ្មែរក៏មិនងាយងាកចេញពីព្រះពុទ្ធសាសនានោះដែរ ប៉ុន្តែព្រះសង្ឃគួរមានមធ្យោបាយរបៀបណាដើម្បីចូលរួមកាត់បន្ថយនូវភាពក្រីក្រ និងចូលរួមដោះស្រាយបញ្ហាកំពុងប្រឈមមុខរបស់ប្រជាពលរដ្ឋដែលបាននិងកំពុងកើតមាននៅពេលនេះ ។

## ១-សំណួរ

1-តើព្រះសង្ឃធ្លាប់មានប្រពៃណីអភិវឌ្ឍន៍សហគមន៍មែនឬទេ ? ដូចជាជួយអ្វីខ្លះ ? តើការជួយនេះទាក់ទងនឹងសិទ្ធិអ្វីខ្លះ ?

2-តើប្រជាពលរដ្ឋធ្លាក់ក្នុងសភាពក្រីក្រមែនឬទេ ? មកពីហេតុអ្វី ? (ជាគំនិតផ្ទាល់របស់អ្នកចូលរួម)

3-តើប្រជាពលរដ្ឋកំពុងជួបប្រទះឬប្រឈមមុខនឹងបញ្ហាអ្វីខ្លះ ? រៀបរាប់បង្ហាញ ។

4-តើទស្សនៈនៅក្នុងអត្ថបទនេះចង់សំណូមពរដល់អ្នកណា ? ឱ្យជួយអ្វីខ្លះ ? បន្ទាប់មកទៀតឱ្យសង្ខេបយកចំណុចសំខាន់ៗអំពីគំនិតនៃទស្សនៈនេះ ថាតើគេផ្តោតទៅលើអ្វី និងចង់បានអ្វីខ្លះ ។





## ២-ករណីសិក្សា

**★ករណីសិក្សាទី១**

| |
|---|
| មានប្រជាពលរដ្ឋជាច្រើនសិបគ្រួសារ ត្រូវបណ្តេញដោយអាជ្ញាធរនៅតំបន់មួយ ឱ្យរុះរើផ្ទះសម្បែង ដើម្បីយកកន្លែងរៀបចំរមណីយដ្ឋាន ដោយបានចោទប្រកាន់ថាពួកនេះរស់នៅមិនស្របច្បាប់ ។ ក្រុមប្រជាពលរដ្ឋទាំងនេះបានអះអាងថា ពួកគេធ្លាប់រស់នៅលើដីនេះ ជាច្រើនឆ្នាំមកហើយ ហើយគេមិនព្រមរុះរើឡើយ ។ អាជ្ញាធរបានបញ្ជាឱ្យក្រុមប្រដាប់អាវុធរុះរើផ្ទះទាំងនោះ ។ ពេលនោះ ដែរមានអ្នកស្រុកខ្លះបានរត់ទៅទូលព្រះសង្ឃជាច្រើនអង្គឱ្យជួយពួកគេ តែមានព្រះសង្ឃមួយអង្គបានតបថា រឿងទំនាស់ជាមួយរដ្ឋអំណាចបែបនេះអាត្មាមិនហ៊ានទេ ណាមួយជារឿងរបស់ឧបាសកឧបាសិកា ហើយក៏មិនដឹងថាអ្នកណាខុសអ្នកណាត្រូវផងដែរ ។ |

**★ពិភាក្សាតាមក្រុមៈ**

1-តើប្រជាពលរដ្ឋទាំងនោះ កំពុងតែប្រឈមមុខទៅនឹងបញ្ហាអ្វីខ្លះ ?

2-តើព្រះអង្គមានព្រះទ័យយល់ឃើញដូចព្រះសង្ឃមួយអង្គនោះដែរឬទេ ? ហេតុអ្វី ?

3-បើសិនជាព្រះអង្គមិនយល់ឃើញដូចព្រះសង្ឃមួយអង្គនោះទេ ពិតជាព្រះអង្គរួមចំណែកដើម្បីជួយដោះស្រាយពួកគេហើយ តើការជួយនោះព្រះអង្គមានវិធីដូចម្តេចខ្លះ ដើម្បីភាពយុត្តិធម៌ក្នុងនាមព្រះអង្គជាសង្ឃ ? បង្ហាញពីវិធីដែលជួយសំរួល ។

**★ករណីសិក្សាទី២**

| |
|---|
| នៅក្នុងឃុំដាច់ស្រយាលមួយមានអារាមពីរ និងការរស់នៅរបស់ប្រជាពលរដ្ឋកំពុងតែជួបប្រទះនឹងបញ្ហាដូចជា ខ្វះទឹកប្រើប្រាស់សំរាប់គ្រួសារ គឺនៅក្នុងភូមិខ្លះមានអណ្តូងទឹកតែមួយប៉ុណ្ណោះ ភូមិខ្លះប្រើស្រះ-ត្រពាំង មានទឹកល្អក់ខ្វល់ ហើយខែរាំងស្ងួត កន្លែងមានទឹកគឺនៅបឹងឆ្ងាយពីភូមិ ។ ចំណែកផ្ទះសម្បែង ខ្ទមរយីករយាកពេលភ្លៀងលិចតាមដំបូល ។ នៅពេលឈឺថ្កាត់មន្ទីរពេទ្យនៅឆ្ងាយជូនកាលអ្នកជម្ងឺស្លាប់តាមផ្លូវ ជូនកាលទៅដល់ពេទ្យហើយមន្ទីរពេទ្យខ្វះថ្នាំព្យាបាល ។ |

ចំណែកផ្លូវទាក់ទង ពីភូមិមួយទៅភូមិមួយ រលុះរលាញ ប៉ប៉ុចប៉ប៉ាច់ជាប់ស្អិតពេលភ្លៀង រីឯសាលារៀន ជញ្ជាំងធ្លុះធ្លាយ ដំបូលលិច បាក់បែក ខ្វះតុ-កៅអី ។ល។ បើតាមតួនាទី ភារកិច្ច-ភារកិច្ចសំរាប់ជាមធ្យោបាយអភិវឌ្ឍន៍គឺជារឿងរបស់រដ្ឋាភិបាលនិងសង្គមស៊ីវិល ព្រមទាំងប្រជាពលរដ្ឋខ្លួនឯងដែលត្រូវតែដោះស្រាយ ។ ក៏ប៉ុន្តែមានមតិមួយបានលើកឡើងថា រដ្ឋាភិបាលថ្នាក់លើមិនអាចពិនិត្យមើលសព្វគ្រប់ជ្រុងជ្រោយឡើយ និងសង្គមស៊ីវិលមិនសូវមានតាំងនៅតំបន់ដាច់ស្រយាល រីឯរដ្ឋអំណាចមូលដ្ឋានខ្លះខ្វះការទំនាក់ទំនង និងប្រជាពលរដ្ឋមួយចំនួនខ្វះការយល់ដឹង ខ្លះសុញគំនិតតាមដំណើរ ។ ដូច្នេះ តើភូមិ-ឃុំទាំងនោះនឹងត្រូវបានដោះស្រាយដូចម្តេចដើម្បីសំរួលការរស់នៅឱ្យកាន់តែប្រសើរឡើង ។

***ពិភាក្សាតាមក្រុម :**

1-តើប្រជាពលរដ្ឋនៅក្នុងឃុំនោះ កំពុងប្រឈមមុខទៅនឹងបញ្ហាអ្វីខ្លះ ?

2-តើអ្នកណាមានតួនាទីជាអាទិភាពក្នុងការដោះស្រាយបញ្ហាទាំងនោះ ? រដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាល ?

3-ព្រះសង្ឃក៏អាចមានតួនាទីយ៉ាងសំខាន់ណាស់ដែរក្នុងការជួយពុទ្ធបរិស័ទ ព្រោះ " ពុទ្ធបរិស័ទអាស្រ័យព្រះសង្ឃ ឬព្រះសង្ឃអាស្រ័យនឹងពុទ្ធបរិស័ទ " ដូច្នេះយោងតាមចំណុចនីមួយៗដែលប្រជាពលរដ្ឋកំពុងតែប្រឈមមុខនេះ តើព្រះសង្ឃអាចជួយដោះស្រាយបានតាមរបៀបណា ? និងអាចធ្វើអ្វីបាន ? សូមព្រះអង្គបង្ហាញវិធីជួយទៅលើចំណុចនីមួយៗដែលកំពុងខ្វះខាតនោះ ធ្វើឱ្យមានភាពប្រសើរឡើង ។

**៣-សំនួរបញ្ចប់ :**

1- តើព្រះអង្គបានសិក្សាអំពីអ្វីខ្លះ អំបាញ់មិញនេះ ?

2-តើព្រះអង្គមានព្រះទ័យដូចម្តេចដែរ ដែលសំណូមពរឱ្យព្រះអង្គចូលរួមដោះស្រាយជីវភាពរស់នៅរបស់ពុទ្ធបរិស័ទដែលកំពុងតែប្រឈមមុខនឹងការខ្វះខាតនេះ ?

II.**អត្ថបទជំនួយ :**

## ១-បញ្ជីសិទ្ធិសេដ្ឋកិច្ច-សង្គម និងវប្បធម៌មួយចំនួន :





| សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ |
|---|
| -សិទ្ធិមានចំណីអាហារគ្រប់គ្រាន់ |
| -សិទ្ធិទទួលបាននូវលក្ខខណ្ឌរស់នៅសមរម្យ |
| -សិទ្ធិមានការគាំពារខាងសុខភាព |
| -សិទ្ធិមានផ្ទះសម្បែងនិងកម្មសិទ្ធិដីធ្លី |
| -សិទ្ធិទទួលបានការអប់រំ |
| -សិទ្ធិមានការងារធ្វើ |
| -សិទ្ធិមានប្រាក់កំរៃស្មើគ្នាចំពោះការងារដូចគ្នា |
| -សិទ្ធិមិនរងការបង្ខិតបង្ខំឱ្យធ្វើការហួសកម្លាំង |
| -សិទ្ធិបង្កើតសហជីព |
| -សិទ្ធិសំរាកលំហែវិស្សមកាល ឬ មាតុភាព |
| -សិទ្ធិសំដែងឬមានមនោសញ្ចេតនាទៅលើវប្បធម៌ |

**២-ការងារនិងបទពិសោធន៍នៃអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍** (អត្ថបទដកស្រង់ពីសិក្ខាសាលាជាតិលើកទី២ ឆ្នាំ១៩៩៥ ស្តីពី " ពុទ្ធសាសនា និង ការអភិវឌ្ឍន៍សង្គមខ្មែរ និងឧទ្ទេសនាមដោយ ភិក្ខុចិរត្ថចិត្តោ ស៊ុយសឿម)(ដោយគ្រាន់តែជាឧទាហរណ៍គំរូមួយសំរាប់ព្រះអង្គធ្វើការពិចារណាតែប៉ុណ្ណោះ) ខាងក្រោមនេះ ជាការដកស្រង់ពុទ្ធដីកាខ្លះៗ :

ដោយយល់ឃើញថាព្រះពុទ្ធសាសនាពិតជាមានលក្ខណៈជាមគ្គុទេសក៍សមស្រប ព្រមទាំងមានប្រសិទ្ធិភាពខ្ពស់ក្នុងការធ្វើអភិវឌ្ឍន៍សង្គមខ្មែរ ទើបនៅឆ្នាំ១៩៩០ក្រុមព្រះសង្ឃនិងឃរាវាសមួយ (គ្រហស្ថ) ក្រុមបានរួមគ្នាបង្កើតជាអង្គការក្រៅរដ្ឋាភិបាលមួយ ដោយមានឈ្មោះថា " ពុទ្ធសាសនាដើម្បី អភិវឌ្ឍន៍" ។

គោលបំណងគឺ ដើម្បីលើកស្ទួយនិងបង្កើនគុណភាពជីវភាពពលរដ្ឋខ្មែរ លើវិស័យ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងមានសកម្មភាពដូចខាងក្រោមនេះ ៖

1-មត្តេយ្យសិក្សា ៖ ការកាត់បន្ថយចុះនូវការមិនចេះអក្សររបស់កុមារ អាទិភាពទៅលើគ្រួសារក្រីក្រ កុមារកំព្រា ។ល។

2-ធនាគារស្រូវ ៖ បន្ធូរភាពទាល់ច្រករបស់កសិករក្រីក្រ ក្នុងកង្វះខាតស្រូវពូជ ជួយកាត់បន្ថយអត្រាការស្រូវដ៏ខ្ពស់ដែលអ្នកស្រុកធ្លាប់រងគ្រោះកន្លងមក ។

3-អប់រំសុខភាពចល័ត ៖ ជំរុញអ្នកស្រុកឱ្យអនុវត្តអនាម័យ និងយល់ដឹងពីវិធីការពារទប់ទល់នឹងជម្ងឺផ្សេងៗ ។

4-ធនាគារគោក្របី ៖ បង្កើតឡើងសំរាប់ឧបត្ថម្ភចំពោះគ្រួសារណាដែលពុំមានគោក្របី ប្រើប្រាស់ ក្នុងការងារកសិកម្ម ។

5-រុក្ខវប្បកម្ម ៖ បណ្តុះបណ្តាលប្រជាពលរដ្ឋ ឱ្យយកចិត្តដាក់ក្នុង ការដាំដុះ និងថែរក្សាការពាររុក្ខជាតិ គ្រប់ប្រភេទ ។



*ការដាំដុះនិងថែរក្សាការពាររុក្ខជាតិ*

6-យុវជននិងសីលធម៌ ៖ ជាកម្មវិធីលើកកំពស់ផ្នែកសីលធម៌សង្គម គុណភាពផ្លូវចិត្ត និងសតិបញ្ញា ជួយដល់យុវជន ឱ្យក្លាយទៅជា ជន្ទល់ដ៏រឹងមាំសំរាប់ប្រទេសជាតិ ។

7-អប់រំព្រះសង្ឃ ៖ប្រគេនចំណេះដឹងដល់ព្រះសង្ឃ ផ្នែកផ្លូវលោកនិងផ្លូវធម៌ ដើម្បីឱ្យលោកក្លាយទៅជាសសរទ្រូងនៃព្រះពុទ្ធសាសនា ។

8-សង្គមសង្គ្រោះ ៖ ជួយដល់ទុគតិជនម្តងម្កាល ដើម្បីបង្កលក្ខណៈឱ្យគេជួយខ្លួនឯងបាន ក្រៅពីនេះ មានកម្មវិធីស្បៀងពលកម្ម ធ្វើថ្នល់ សង់សាលារៀន ព្រមទាំងបុណ្យទានផ្សេងៗ ។

**៣-ពុទ្ធវចនៈ**

នៅក្នុងសម័យព្រះ មានភិក្ខុ-សាមណេរសួរថា អ្វីជាធម៌ ? សាមណេរមួយអង្គឆ្លើយថា **សព្វេសត្តា អាហារដ្ឋិតិកា** គឺការបរិភោគហ្នឹងឯងជា ធម៌ កាលណាខ្វះបរិភោគហើយ ធ្វើអ្វីមិនកើតទេ។






*ព្រះសង្ឃកំពុងបណ្ដុះកូនរុក្ខជាតិ*

**ចប់**

# លុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ

## I.ទស្សនៈ

ការរើសអើងគឺជាការប្រកាន់វណ្ណៈ ប្រាសមកវិញការប្រកាន់វណ្ណៈ នាំឱ្យមានការរើសអើង ។



បញ្ហារើសអើងឬការប្រកាន់វណ្ណៈ មានច្រើនសណ្ឋាននៅក្នុងសង្គមមនុស្សដូចជា រវាងអ្នកមាននិងអ្នកក្រ រវាងអ្នកធំនិងអ្នកតូច រវាងពូជសាសន៍និងពូជសាសន៍ ។ល។ ក៏ប៉ុន្តែមានបញ្ហារើសអើងដ៏ធំមួយរបស់សង្គម ហើយដែលមនុស្សភាគច្រើនកម្រនឹងយល់ឃើញនោះ គឺជាការរើសអើងរវាងបុរសនឹងស្ត្រី ។ តើវាជាបញ្ហាពិតដូច្នេះមែនទេ នៅក្នុងសង្គមខ្មែរនោះ ?

គំនិតខ្មែរភាគច្រើនៗតែងតែអះអាងថា " ប្រពៃណីទំនៀមទម្លាប់ខ្មែរល្អណាស់ "ក្នុងការអប់រំសង្គមកន្លងមក វាជាការពិតណាស់ ក៏ប៉ុន្តែក្នុងលោកនេះក៏មិនមានអ្វីល្អឥតខ្ចោះនោះដែរ បានន័យថា វាមិនមែនមានតែគុណសម្បត្តិទាំងអស់នោះទេ ព្រោះអ្វីក៏ដោយគឺមនុស្សជាអ្នកបង្កើត-អ្នកកំណត់ គឺវាត្រូវតែមានគុណវិបត្តិជាប់ជាមួយ គ្រាន់តែតិចហើយនិងច្រើនប៉ុណ្ណោះ ។ ដូច្នេះទំនៀមទំលាប់របស់យើងក៏វាមិនពិតថាគ្មានចំណុចខ្សោយនោះដែរ ។

សូមពិចារណាទៅលើចំណុចមួយ ក្នុងចំណោមចំណុចដទៃទៀតជាច្រើន នៃទម្លាប់របស់ខ្មែរ ដែលតែងតែគិតថា កូនស្រីមិនបាច់ឱ្យទៅរៀនសូត្រចេះដឹងវែងឆ្ងាយ ឬ ក៏ទៅធ្វើចីចុងអីដូចបុរសពេកទេ ចាំតែពឹងពាក់ប្តីទៅបានហើយ ហើយកូនស្រីត្រូវគិតយ៉ាងម៉េចឱ្យតែចេះកិច្ចការផ្ទះឬជាមេផ្ទះដ៏ល្អសំរាប់បំរើប្តីតាមក្បួនតម្រាស្រីទៅបានហើយ ចំណែកបុរសទើបស័ក្តិសម ទោះដើរចេញទៅណាមកណាមិនភ័យមិនព្រួយដូចស្រីឡើយ ហើយបុរសគឺជាអ្នកមានកាតព្វកិច្ច ដែលត្រូវតែស្វែងរកតិរះវិជ្ជាដើម្បីចិញ្ចឹមប្រពន្ធ-កូន ។

ទម្លាប់នេះបានផ្តល់ឱ្យស្ត្រីភាគច្រើនចាំផ្ទះ និងមានមុខរបរធ្វើតែស្រែ-ចំការ-លក់ដូរ ហើយក្រៅពីកិច្ចការនេះមានបន្ទុកមើលថែទាំកូនផង ដាំ-ស្ងួផង ទុកដាក់ផ្ទះសម្បែងផង ។ល។ ដូច្នេះ លទ្ធផលជាមុខមាត់ក្នុងការចូលរួម ឬដឹកនាំដើម្បីជួយអភិវឌ្ឍន៍សង្គម និងរកប្រាក់ចំណូលគ្រួសារ ភាគច្រើនស្ថិតក្នុងកណ្តាប់ដៃបុរស ។ ឧទាហរណ៍ សូម្បីតែយាយជីក៏កម្រមាននៅក្នុងគណៈកម្មការវត្តដែរកុំថាឡើយដល់ទៅប្រធានគណៈកម្មការវត្តនោះ។

ទម្រង់ទាំងនេះហើយ ដែលជាទម្លាប់របស់សង្គមបង្ហាញឱ្យឃើញថាបុរសជាអ្នកខ្លាំង បុរសពោរពេញទៅដោយកម្លាំងពលំ ។ ដូច្នេះផលប៉ះពាល់នាំឱ្យមានភាពបន្ទុះបង្អាប់ មានការរើសអើងដល់ភេទមួយទៀតដូចជាថា ស្ត្រីទន់ខ្សោយ ស្ត្រីខ្វះភាពក្លាហាន និងមិនអាចធ្វើអ្វីបានប្រសើរឡើយ ។ ដោយសារតែចំណុចទាំងនេះបណ្តាលឱ្យស្ត្រីភាគច្រើនរងនូវអំពើទារុណកម្មពីប្តី ហើយមានខ្លះរហូតដល់ប្តីសម្លាប់ទៀតផង ។ ម្យ៉ាងវិញទៀតរហូតមកដល់បច្ចុប្បន្ននេះ ដោយសារតែទម្លាប់ ក៏នៅតែធ្វើឱ្យស្ត្រីខ្លះ ខ្វះទំនុកចិត្តខ្លួនឯង និងមិនសូវមានជំនឿលើស្ត្រីគ្នាឯងនៅឡើយ សំរាប់តួនាទីផ្សេងៗ នៅក្នុងសង្គមក៏ដូចជាតួនាទីនៅក្នុងគ្រួសារដែរ ។




ទស្សនៈសិទ្ធិមនុស្សបានអះអាងថា ស្ត្រីនិងបុរសជាមនុស្សដូចគ្នា មានសិទ្ធិនិងសេចក្តីថ្លៃថ្នូរដូចៗគ្នាតាំងពីកំណើត គ្រាន់តែមានភេទផ្ទុយគ្នាប៉ុណ្ណោះ តើមកពីហេតុអ្វីបានជាធ្វើឱ្យមានវិសមភាពរវាងភេទទាំងពីរ ? តើវាអាចកែប្រែបានឬទេ ? កែប្រែដោយរបៀបណា ?

?

**១-សំណួរ :**

★ទស្សនៈនៃទំនៀមមួយបានលើកឡើងថា" ឪពុកម្ដាយភាគច្រើន ស្រលាញ់កូនស្រីណាស់ មិនចង់ឱ្យចេញពីផ្ទះទៅណាឆ្ងាយដូចបុរសទេ ព្រោះគ្នាជាស្រីភេទទន់ខ្សោយ ហើយពេលមានប្ដីសីទៅ បានប្ដីចិញ្ចឹមហើយ ។

ក/ទស្សនៈតាមទំនៀមទម្លាប់នេះ ផ្ដល់ផលល្អដូចម្ដេចខ្លះដល់កូនស្រី ?

ខ/ទស្សនៈនេះផ្ដល់ផលអាក្រក់ដូចម្ដេចខ្លះដល់កូនស្រី ?

គ/គួរជ្រើសរើសយកទស្សនៈមួយណាទាំងពីរខាងលើ ? ហេតុអ្វី ?

**២-ពិភាក្សាសំណួរខាងក្រោមនេះ ដោយបែងចែកជាក្រុម :**

**★សំរាប់ក្រុមទី១**

1-ពិភាក្សាភាពដូចគ្នារវាងបុរសនិងស្ត្រី ។

2-ពិភាក្សាភាពខុសគ្នារវាងបុរសនិងស្ត្រី ។

3-រវាងបុរសនិងស្ត្រី ចំណុចដែលមិនអាចកែប្រែបាន និងអាចកែប្រែបាន ។ ហេតុអ្វី ?

4-អ្វីទៅដែលហៅថាភេទ ? និងអ្វីទៅដែលហៅថា យេនឌ័រ ?

**★សំរាប់ក្រុមទី២**

1-រៀបរាប់កិច្ចការនិងកាតព្វកិច្ចដែលបុរសត្រូវធ្វើនិងមិនត្រូវធ្វើ ហេតុអ្វី ។

2-រៀបរាប់មុខការឬជាកាតព្វកិច្ចរបស់ស្ត្រីដែលត្រូវតែធ្វើ ហេតុអ្វី ។ កិច្ចការណាដែលស្ត្រីមិនត្រូវធ្វើ ហេតុអ្វី ?

3-រវាងមុខការទាំងពីរ តើមានមុខការណាអាចផ្លាស់ប្ដូរគ្នាបានទេ ? ហេតុអ្វី ?

4-អ្វីទៅហៅថាភេទ ?

**១ក-អ្វីទៅដែលហៅថាភេទ** ? សំដៅលើភាពខុសគ្នាផ្នែកជីវសាស្ត្រ (ធម្មជាតិផ្តល់ឱ្យមានភេទប្រុស និងភេទស្រី មិនអាចផ្លាស់ប្តូរបាន) ។

**១ខ-អ្វីទៅដែលហៅថាយេនឌ័រ** ? វាមិនមែនជាកត្តាជីវសាស្ត្រទេ គឺសំដៅទៅលើភាពខុសប្លែកគ្នារវាងបុរសនិងស្ត្រីដែលត្រូវបានកំណត់ដោយសង្គម និងបានដឹងដោយខ្លួនឯងតាមរយៈសង្គម



និងមានការប្រែប្រួលពីពេលមួយទៅពេលមួយទៀត ។ យេនឌ័រអាចមានការផ្លាស់ប្តូរយ៉ាងទូលំទូលាយរវាងតួនាទីបុរសនិងស្ត្រីទៅតាមវប្បធម៌នៅក្នុងសង្គម និង រវាងវប្បធម៌មួយទៅវប្បធម៌មួយទៀត ។

យេនឌ័រគឺជាគោលគំនិតផ្នែកសេដ្ឋកិច្ចសង្គម ក្នុងការវិភាគលើតួនាទី ទំនួលខុសត្រូវ ឧបសគ្គ ឱកាស និងតម្រូវការរបស់បុរស-ស្ត្រីនៅគ្រប់បរិបទទាំងអស់ ។

**១គ-តម្រូវការយេនឌ័រ**

ការតម្រូវឱ្យមានយេនឌ័រគឺជាស្ថានភាពសុក្រិតដែលក្នុងនោះស្ត្រីនិងបុរសមានឱកាសស្មើគ្នា សិទ្ធិស្មើគ្នា អំណាចស្មើគ្នា ចែករំលែកការទទួលខុសត្រូវស្មើគ្នា មានតួនាទីស្មើគ្នា នៅក្នុងគ្រួសារ ក្នុងសង្គម និងនៅក្នុងសហគមន៍ ។

**១ឃ-គោលដៅយេនឌ័រ**

***ក/តម្រូវការយេនឌ័រជាក់ស្តែង :***

គឺជាការឆ្លើយតបមួយចំពោះសេចក្តីត្រូវការជាចាំបាច់ភ្លាមៗ និងជាបន្ទាន់សំរាប់ស្ត្រីដែលពាក់ពន្ធ័ទៅនឹងភាពមិនគ្រប់គ្រាន់នៅក្នុងស្ថានភាពរស់នៅ ការថែទាំសុខភាព និងការបំពេញការងាររបស់ពួកគេ ។

**ខ/ឥឡូវការយេនឌ័រជាយុទ្ធសាស្ត្រ :**

គឺជាការផ្តល់ឱកាសឱ្យស្ត្រីទទួលបាននូវសមធម៌ និង សមភាពយេនឌ័រ ទាក់ទងទៅនឹងពលកម្ម ការងារ ការបែងចែកអំណាច តួនាទី នៅក្នុងគ្រួសារ ក្នុងរដ្ឋ និងក្នុងសង្គម ។

**២.ច្បាប់ការពារសមភាពផ្នែកភេទ :**

**២ក/រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

**+មាត្រា៣៥ (កថាខណ្ឌ១):** ប្រជាពលរដ្ឋទាំងពីរភេទ មានសិទ្ធិចូលរួម យ៉ាងសកម្មក្នុងជីវភាព នយោបាយ សេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

**+មាត្រា៣៦ :** (កថាខណ្ឌ៣) ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

**+មាត្រា៤៥ :**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវលុបបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងារស្ត្រី ត្រូវហាមឃាត់ ។

បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ ។

អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្ដីមួយប្រពន្ធមួយ ។

**២ខ/ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ**

**មាត្រា១ :** ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ដោយផ្អែកលើមាត្រា៧និងមាត្រា៨នៃរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា មានគោលដៅដាក់បទបញ្ញា និងការរៀបអាពាហ៍ពិពាហ៍និងគ្រួសារ ធានាសមភាពរវាងសហពទ្ធ័ក្នុងអាពាហ៍ពិពាហ៍ និងក្នុងជីវភាពគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្ដាយក្នុងការចិញ្ចឹមថែរក្សាកូន និងជំរុញការបណ្តុះបណ្តាលសីលធម៌ និងការអប់រំឱ្យទៅជាពលរដ្ឋល្អមានមនសិការស្នេហាជាតិ ស្រលាញ់ការងារ មានសម្បជញ្ញៈទទួលត្រូវចំពោះសង្គម ។

មាត្រា២៥ :

ក្នុងគ្រួសារ ប្ដីឬប្រពន្ធ ត្រូវមានភាពភាពស្មើគ្នាលើគ្រប់ទស្សនៈ

**២ឥ/ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាសម័យអន្តរកាល :**

**✦មាត្រា៤១** : (អំពើបង្ករបួសដោយចេតនា)ជនណាវាយតប់បណ្ដាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ឬពិការបណ្ដោះអាសន្នរយៈពេលលើសពី៦ខែដោយចេតនា ត្រូវមានទោសពីបទបង្ករបួសស្នាមដោយចេតនា ហើយត្រូវផន្ទាទោស ដាក់គុកពី១ឆ្នាំទៅ៥ឆ្នាំ ។

-បើពិការភាពបណ្ដោះអាសន្នតិចជាង៦ខែ ត្រូវដាក់គុកជននោះពី៦ខែដល់២ឆ្នាំ ។

-បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្ដន្ទាដាក់គុកពី២ខែឡើងទៅ១ឆ្នាំ ។

-បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ ប្រភេទទោសត្រូវកំណត់១ជា២ ។

**២ឃ/កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្ស**

**✦មាត្រា៣** : រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញាទាំងពីរនេះ ត្រូវធានាឱ្យមានភាពស្មើគ្នារវាងបុរសនិងស្ត្រីក្នុងការប្រើសិទ្ធិទាំងអស់ខាងផ្នែក សិទ្ធិពលរដ្ឋ-នយោបាយ និងសិទ្ធិសេដ្ឋកិច្ច-សង្គម និងវប្បធម៌ ។



**ចប់**

# សិទ្ធិអប្បរភាគជន

## I. ឧស្សនៈ

នៅក្នុងប្រទេសណាក៏ដោយតែងតែមានជានិច្ច ការរស់នៅរបស់ពូជសាសន៍ ដូចជា : អន្ដោប្រាម (ជាម្ចាស់ស្រុកដើម), ជាតិពន្ធ (ជាតិសាសន៍ដទៃដែលបានរស់នៅតំណរក្នុងប្រទេសណាមួយ) , អន្ដោប្រវេសន៍ (ជនទាំងឡាយណាដែលមកសុំរស់នៅប្រទេសណាមួយក្រៅពីប្រទេសរបស់ខ្លួន) ឬ ជនភៀសខ្លួន (ជនសុំជ្រកកោនប្រទេសណាមួយដែលប្រទេសខ្លួនមានសង្គ្រាម ឬកើតភាពវិកវរ ចលាចលអំពីអ្វីមួយ) ។



សំរាប់ប្រទេសកម្ពុជា ក៏មានការរស់នៅរបស់ក្រុមទាំងនេះ ដូចជាពួកអន្ដោប្រាម មាន ភ្នង គួយ ចារ៉ាយ ។ល។ និងជាតិពន្ធ មាន ចាម ចិន វៀតណាម ។ល។ រីឯពួកអន្ដោប្រវេសន៍ និង ជនភៀសខ្លួនដែលសម្បូរជាងគេនៅកម្ពុជានោះ គឺជនជាតិវៀតណាម ។

សិទ្ធិមនុស្សបានចែងថា "មនុស្សទាំងអស់មិនត្រូវបានគេបែងចែកឱ្យខុស១ពីគ្នា ដោយប្រកាន់ទៅលើជាតិសាសន៍-ពណ៌សម្បុរ-វណ្ណៈ-អ្នកមាន-អ្នកក្រ-ភាសា-សាសនា និង មតិនយោបាយអ្វីឡើយ" ។ ធម៌បាលីរបស់ព្រះសម្មាសម្ពុទ្ធមានពុទ្ធដីកាថា **វសលៈ ឬ វសលី** (អានថាវ៉ាក់សាក់ ឡាក់ និង វ៉ាក់សាក់ឡី) មានន័យថាមនុស្សជាតិទាប ឬមនុស្សសូទ្រ គឺជាពាក្យអាសគ្រាម គឺជាសម្ដីពុំគួរសមឡើយ ។ ព្រះពុទ្ធដីកាទូន្មាននេះក៏អាចមានន័យថា មិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ប្រភពជាតិ ឬសង្គម ធនធាន កំណើត ឬស្ថានភាពដទៃទៀតឡើយ ។ ដូច្នេះ តាមរយៈផ្លូវលោកក្ដី និងផ្លូវធម៌ក្ដី មនុស្សទាំងអស់ មិនថាមានភាគតិច ឬភាគច្រើន ទេ គឺត្រូវទទួលបាននូវ សិទ្ធិនិងសេចក្ដីថ្លៃថ្នូរដូច១គ្នាតាំងពីកំណើត ព្រមទាំងត្រូវទទួលបាននូវសិទ្ធិ ឱ្យគេទទួលស្គាល់ខ្លួនជាមនុស្សពេញ លក្ខណៈច្បាប់ ទោះបីនៅទីកន្លែងណាក៏ដោយ ។

និយាយដោយឡែក មនុស្សមានសិទ្ធិក្នុងការចេញចូលប្រទេសណាមួយ ដើម្បីសុំជ្រកកោនស្របច្បាប់ បែបជាអន្តោប្រវេសន៍ ឬ ក៏ក្នុងឋានៈជាជនភៀសខ្លួន ក៏ប៉ុន្តែរឿងអនុញ្ញាតឬមិនអនុញ្ញាត វាអាស្រ័យដោយច្បាប់របស់ប្រទេសនីមួយៗនោះ ។ ដូច្នេះការចេញចូលរបស់ជនបរទេសមកក្នុងប្រទេសណាមួយ វាជាអំណាចរបស់រដ្ឋាភិបាលប្រទេសនោះ ដែលទទួលខុសត្រូវលើកិច្ចការនេះ ក៏ប៉ុន្តែបន្ទាប់ពីពួកគេត្រូវបានអនុញ្ញាតឱ្យរស់នៅហើយ ឬទោះបីអ្នកនោះលបចូលមកតាមវិធីណាក៏ដោយ ពួកគេត្រូវបានទទួលសិទ្ធិមនុស្សដូចមនុស្សទូទៅដែរ លើកលែងតែករណីខ្លះដែលទាក់ទងជុំវិញទៅនឹងសិទ្ធិបោះឆ្នោតតែប៉ុណ្ណោះ សិទ្ធិនេះលុះត្រាតែគេត្រូវបានទទួលឱ្យចូលសញ្ជាតិហើយសិន ។ម្យ៉ាងវិញទៀត ពួកគេក៏មិនត្រូវទទួលរងនូវការរំលោភផ្សេងៗ ឬក៏ត្រូវបំបិទសិទ្ធិសេរីភាពអ្វីនោះ ឡើយ តែពួកគេក៏ត្រូវទទួលការអប់រំអំពីសិទ្ធិរស់នៅ ក៏ដូចជាធ្វើឱ្យចេះគោរពសិទ្ធិអ្នកដទៃ ផងដែរ ។

ដូច្នេះក្នុងនាមម្ចាស់ស្រុក គួរចេះគោរពសិទ្ធិមនុស្សដល់ជនជាតិភាគតិចទាំងនោះ ព្រោះគេជាមនុស្សដូចយើងដែរ ដែលត្រូវតែទទួលបាននូវសិទ្ធិផ្សេងៗទាក់ទងទៅនឹងសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ ជាពិសេសសិទ្ធិសំខាន់បីរបស់ពួកគេដូចជា ភាសា សាសនា និងទំនៀមទម្លាប់ជាដើម ដែលចាំបាច់ពួកគេត្រូវតែមាន រីឯនីតិវិធីផ្សេងៗដែលត្រូវដោះស្រាយចំពោះអ្នកចូលមក ទោះស្របច្បាប់ក្ដី និងមិនស្របច្បាប់ក្ដីគឺជារឿងរបស់រដ្ឋាភិបាល ។

ព្រះសង្ឃគួរតែចាប់អារម្មណ៍នូវរឿងនេះ ហើយនិងជួយអប់រំដល់ពុទ្ធបរិស័ទឱ្យបានយល់ដឹងផងដែរ ទោះបីពួកគេជាជាតិពន្ធ ជាអន្តោប្រវេសន៍យ៉ាងណាក៏ដោយ ពួកគេមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិរៀនសូត្រភាសា ប្រពៃណី ប្រវត្តិសាស្ត្រ និងវប្បធម៌របស់ពួកគេ និងសិទ្ធិចូលរួមក្នុងជីវភាពសង្គម និងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស សិទ្ធិបង្កើតនិងរក្សាសមាគម សិទ្ធិទាក់ទងដោយសេរីនិងសន្តិវិធីជាមួយសមាជិកនិងក្រុមគ្រួសាររបស់គេ ។ អំពើប្រឆាំងណាមួយ ឬរើសអើងទៅលើពួកទាំងនេះ នាំឱ្យមានអស្ថេរភាពការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម វប្បធម៌ និង នយោបាយ ឬក៏នាំឱ្យប្រទេសជាតិដើរថយក្រោយ ។

**១-សំណួរ :**

1-តើនៅក្នុងសហគមន៍របស់ព្រះអង្គ មានជាតិពន្ធទេ មានអន្តោប្រវេសន៍ទេ ? ជនជាតិអ្វីខ្លះ ? តើពួកគេត្រូវបានរំលោភពីអ្នកស្រុកភូមិឬពីអាជ្ញាធរដែរឬទេ ? តើពួកគេបានបង្កហេតុអ្វីខ្លះ មកលើសហគមន៍ ?

2-តើការរស់នៅរបស់ជាតិពន្ធនៅក្នុងប្រទេសមួយបាត់បង់សិទ្ធិអ្វីខ្លះ ? ហេតុអ្វី ?

3-តើការរស់នៅរបស់អន្តោប្រវេសន៍ នៅក្នុងប្រទេសមួយបាត់បង់សិទ្ធិអ្វីខ្លះ ? ហេតុអ្វី ?

4-បើសិនជាយើងដឹងថាមានជនអន្តោប្រវេសន៍ ចូលមករស់នៅមិនស្របច្បាប់ តើពួកគេនៅមានសិទ្ធិអ្វីខ្លះ ? តើគេមានសិទ្ធិគោរពពិធីបុណ្យប្រពៃណីរបស់គេទេ ?

**២-ករណីសិក្សា :**

**ករណីសិក្សា** : ប្រជាជនវៀតណាមបានហូរចូលមកក្នុងស្រុកយើងជាច្រើនជាមួយកងទ័ពពួកគេ បន្ទាប់ពីឆ្នាំ១៩៧៩មក ។ នៅឆ្នាំ១៩៨៩ ពេលដែលកងទ័ពពួកគេដកត្រលប់ទៅវិញ ប្រជាជនវៀតណាមមួយចំនួនធំមិនត្រលប់ទៅវិញទេ ។ ក្នុងចំណោមជនជាតិវៀតណាមទាំងនោះ មានអ្នកខ្លះបានតាំងទីលំនៅជាផ្ទះទូកខ្សែក្បែរស្ពានព្រះមុនីវង្ស កជាកូនពូនជាចៅ រកស៊ីនេសាទត្រីតាមដងទន្លេបាសាក់ ដែលអ្នកខ្លះក្នុងចំណោមប្រជាជនទាំងនោះមានទាំងអត្តសញ្ញាណបណ្ណ័ជាប្រជាពលរដ្ឋខ្មែរទៀតផង ។ ប្រជាពលរដ្ឋខ្មែរមួយចំនួនតែងតែសម្លឹងទៅជនជាតិវៀតណាមទាំងនោះថា ជាជនអន្តោប្រវេសន៍មិនស្របច្បាប់ ហើយបានរិះគន់ថាមករស់នៅគ្មានសណ្តាប់ធ្នាប់នាំឱ្យប៉ះពាល់ដល់ការរស់នៅរបស់ខ្លួន ប៉ះពាល់ដល់បរិស្ថាន និងសោភ័ណភាពទីក្រុង ។

វាជាការពិតមែន រដ្ឋាភិបាលត្រូវការកែប្រែសោភ័ណភាពទីក្រុង បន្ទាប់មកក៏ប្រកាសប្រាប់ជនជាតិវៀតណាមដែលមានផ្ទះជាទូកខ្សែទាំងនោះ ឱ្យរំកិលចេញពីទីនោះមកក្បែរក្រុងតាខ្មៅ ហើយថែមទាំងជួលមនុស្សមួយចំនួនឱ្យកាត់ផ្តាច់ខ្សែទូកទាំងនោះទៀតផង ដោយប្រាប់អ្នកទាំងនោះថា មកតាំងទីលំនៅអនាធិបតេយ្យខុសច្បាប់ ។ ពេលបណ្តែតទូកមកដល់ក្បែរក្រុងតាខ្មៅត្រូវអ្នកភូមិខ្មែរនៅទីនោះធ្វើបាតុកម្មបណ្តេញពួកគេចេញពីទីនោះទៀត ។ ដោយទ្រាំមិនបាន ជនជាតិវៀតណាមទាំងនោះក៏សំរេចចិត្តទាំងបង្ខំរំកិលចូលទៅប្រទេសវៀតណាមវិញ ។ ពេលទៅដល់ព្រំប្រទល់ អាជ្ញាធរ

វៀតណាមមិនអនុញ្ញាតឱ្យពួកគេចូល ដោយមិនទទួលស្គាល់ពួកនេះឡើយ ហើយអាជ្ញាធរខ្មែរបដិសេធមិនព្រមឱ្យចូលដីខ្មែរវិញ នៅទីនោះពួកគេជួបប្រទះទៅនឹងបញ្ហាជាច្រើន ដូចជាខ្វះម្ហូបអាហារ ទឹកស្អាត ថ្នាំសង្កូវ សាលារៀន ។ល។ ស្របគ្នានោះ មានជនឆ្លៀតឱកាសបានគំរាមទារប្រាក់ដែលពួកគេបំរុងទុកសំរាប់គ្រួសារ ហើយនិងមានអាជ្ញាធរមួយចំនួនបានសម្លុតដកហូតអត្តសញ្ញាណបណ្ណខ្មែរពីពួកនោះដោយសំអាងថា ជនជាតិវៀតណាមទាំងនោះនិយាយខ្មែរមិនច្បាស់ទាំងសាច់ឈាមពណ៌សំបុរ សាសនា ប្រពៃណី ក៏មិនមែនជាលក្ខណៈខ្មែរ ដូច្នេះគ្មានភស្តុតាងអ្វីបង្ហាញថាខ្លួនជាខ្មែរឡើយ ។

**★សំនួរពិភាក្សា :**

**-យោងតាមករណីសិក្សាខាងលើ**

1-តើចំណុចមិនសមស្របក្នុងការរស់នៅរបស់ជនជាតិវៀតណាមគឺអ្វី ?

2-តើទង្វើរបស់អាជ្ញាធរក្នុងការជម្លៀសជនជាតិវៀតណាមតាមទូកខ្សែ មានចំណុចណាដែលសមស្រប និងចំណុចណាដែលមិនសមស្រប ?

3-តើអាជ្ញាធរត្រូវបានដោះស្រាយដូចម្តេច ដើម្បីឱ្យសមស្របក្នុងការជម្លៀសជនជាតិវៀតណាមតាមទូកទាំងនោះ ?

4-តើការរិះគន់របស់ប្រជាពលរដ្ឋខ្មែរទៅលើជនជាតិវៀតណាម សមស្រប ឬ មិនសមស្រប ? ហេតុអ្វី ?

5-តើជនជាតិវៀតណាមទាំងនោះកំពុងប្រឈមមុខទៅនឹងបញ្ហាអ្វីខ្លះ ?

6-តើចំណុចអ្វីខ្លះដែលប៉ះពាល់សិទ្ធិមនុស្សដល់ជនជាតិវៀតណាមទាំងនោះ ?

7-ជាទូទៅ តើព្រះអង្គគួរមានយោបល់ដូចម្តេច ចំពោះជនអន្តោប្រវេសន៍ ដើម្បីធ្វើឱ្យមានភាពកាន់តែប្រសើរឡើងនៅក្នុងប្រទេសកម្ពុជា ?

8-តើព្រះអង្គមានវិធីដូចម្តេចខ្លះ ដើម្បីចូលរួមជួយបំបាត់ទស្សនៈរើសអើងចំពោះជនជាតិភាគតិច ?

**៣-សំនួរបញ្ចប់ :**

1-តើព្រះអង្គបានសិក្សាពីអ្វីខ្លះ អំបាញ់មិញ ?

2-តើព្រះអង្គមានព្រះទ័យដូចម្ដេចចំពោះសាសនាដទៃដែលមាននៅក្នុងប្រទេសកម្ពុជា ?



## II.ច្បាប់ពាក់ព័ន្ធ

**១-សេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្ស**

**មាត្រា២** : មនុស្សទាំងអស់មិនត្រូវបានគេបែងចែកឱ្យខុស១ពីគ្នា ដោយប្រកាន់ទៅលើជាតិសាសន៍ ពណ៌សម្បុរ វណ្ណៈ អ្នកមាន ឬអ្នកក្រ ភាសា សាសនា មតិនយោបាយ ជាដើមឡើយ ។

**២-ច្បាប់អន្តោប្រវេសន៍របស់ប្រទេសកម្ពុជា**

**មាត្រា២** : ត្រូវចាត់ទុកជាជនបរទេស ជនណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានរើសអើង ទោះបីជននោះមានសញ្ជាតិ ជំនឿសាសនា ឬមានដើមកំណើតណាមួយក៏ដោយ ។

**មាត្រា៥** : ការគ្រប់គ្រងជនបរទេសជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។ ក្រសួងនេះត្រូវមានស្ថាប័នមួយដើម្បីទទួលកិច្ចការអន្តោប្រវេសន៍ ។

**មាត្រា២៩** : ជនបរទេសណាដែលគ្មានការអនុញ្ញាត ហើយចូលមករស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយលបលាក់បន្លំ ឬដោយល្បិចផ្សេងទៀត ផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់គុក ពី ៣ខែដល់ ៦ខែ មុននឹងត្រូវបណ្តេញចេញ ។

**មាត្រា៣៧** : រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសណាដែលចូលក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ។

**៣-ច្បាប់សញ្ជាតិ :**

**មាត្រា៨** : ជនបរទេសដែលអាចសុំសញ្ជាតិតូបនិយកម្មបាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ :

1-មានលិខិតបញ្ជាក់ថាមានគំនិតមារយាទនិងសីលធម៌ល្អដែលចេញដោយមេឃុំ ឬចៅសង្កាត់នៃទីលំនៅរបស់ខ្លួន ។

2-មានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលមានទោសពីបទព្រហ្មទណ្ឌណាមួយ ។

3-មានលិខិតបញ្ជាក់ថា ជននោះមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួន **ប្រាំពីរឆ្នាំ** ដោយគិតពីថ្ងៃដែលបានទទួលបណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ។

4-មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដាក់ពាក្យសុំសញ្ជាតិតូបនិយកម្ម ។

5-ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងច្បាស់ថា ខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ខ្មែរ ។

6-មានបញ្ញានិងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ឬនាំឱ្យមានបន្ទុកដល់ជាតិ ។

## ៤-ច្បាប់ភូមិបាលរបស់ព្រះរាជាណាចក្រកម្ពុជា

**មាត្រា៥** : គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ ។ ការដកហូតនេះត្រូវធ្វើទៅតាមទម្រង់និងនីតិវិធីបញ្ញត្តិដោយច្បាប់ និង បទបញ្ជា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា១៥** : (កថាខ័ណ្ឌ១-៤) រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន និងត្រើយសមុទ្រ ។

-ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅដូចជាតីរឋាន កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ ។

-ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជាផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារនិងឧទ្យានសាធារណៈនិងដីចំណី ។

-ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសំរាប់សេវាសាធារណៈដូចជា សាលារៀនឬអាគារសិក្សាសាធារណៈ អាគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ ។

**៥-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៤៤ :**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិដីធ្លី ។ កម្មសិទ្ធិឯកជនស្របច្បាប់ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតសិទ្ធិពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យនិងយុត្តិធម៌ ។



**ចប់**

# ការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារ

## I. ឧស្សាហ៍:

ទំនៀមមួយឃ្លាដូចខាងដើម បានពោលថា " ព្រះសង្ឃអាស្រ័យពុទ្ធបរិស័ទ រីឯពុទ្ធបរិស័ទក៏អាស្រ័យព្រះសង្ឃវិញដែរ " ក៏ដូចជាមានន័យថា ព្រះពុទ្ធសាសនា មិនអាចផ្តាច់ចេញពីឧបាសក-ឧបាសិកាបានឡើយ ។ ហេតុដូច្នេះហើយ តាមរយៈការបង្កើនសមត្ថភាពអំពីសិទ្ធិមនុស្ស ព្រះសង្ឃគួរតែត្រូវបានយកចំណេះដឹងទាំងនេះទៅអប់រំបន្តដល់ពុទ្ធបរិស័ទ ឬជួយសហការដ៏ខ្ពស់បំផុត ក្នុងការជួយញាតិញោមនៅពេលមានទុក្ខលំបាក ឬ នៅពេលណាដែលមានការរំលោភមកលើសិទ្ធិពលរដ្ឋ-នយោបាយ និង សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់ពួកគេ ។



*(ព្រះសង្ឃអប់រំដល់ប្រជាពលរដ្ឋ)*

ដូចព្រះសង្ឃគ្រប់ព្រះអង្គបានជ្រាបហើយថា តាមរយៈរដ្ឋធម្មនុញ្ញឬហៅថាច្បាប់កំពូល ព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់និងគោរពសិទ្ធិមនុស្ស និងជាពិសេសប្រកាន់យកនូវរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្សទៀតផង ដូច្នេះបានន័យថា សិទ្ធិមនុស្ស និង ប្រជាធិបតេយ្យគឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូប ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ទាំងសិទ្ធិមនុស្ស ទាំងប្រជាធិបតេយ្យ វានឹងអាចស្លាប់ទៅវិញ បើសិនជាគង្វះចលនាឬសកម្មភាពដើម្បីយកវាទៅប្រើប្រាស់ឱ្យបានសមស្របទេនោះ ។ យ៉ាងណាមិញ! ដើម្បីការពារសិទ្ធិមនុស្ស និងប្រជាធិបតេយ្យឱ្យបានគង់វង្ស លុះត្រាតែពលរដ្ឋទាំងអស់សាមគ្គីគ្នា ហ៊ានបញ្ចេញសកម្មភាពរបស់ខ្លួនដើម្បីកែប្រែនូវអ្វីៗនៅពេលណាដែលអំពើអយុត្តិធម៌ ឬអំពើរំលោភនានាបានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ ។ម្យ៉ាងវិញទៀត គឺខិតខំតស៊ូរកឱ្យឃើញនូវតម្លាភាព យុត្តិធម៌សង្គម ដែលជាសេចក្តីប្រាថ្នារបស់មនុស្សរាល់រូបមិនថាគ្រហស្ថឬបព្វជិតឡើយ ។

សរុបសេចក្តីមក នៅក្នុងសង្គមជាតិ ព្រះសង្ឃមានតួនាទីសំខាន់ណាស់ ដោយកន្លងមកព្រះអង្គតែងតែមានព្រះទ័យយកចិត្តទុកដាក់ និងបានជួយដឹកនាំ អប់រំ បំភ្លឺផ្លូវដល់ពុទ្ធបរិស័ទជានិច្ច ឱ្យសន្សំតែសេចក្តីសុខ សេចក្តីរីកចំរើន ដែលជាគោលការណ៍ចម្បងបំផុតរបស់ព្រះពុទ្ធសាសនា ។ ដូច្នេះអ្វីដែលជាយុទ្ធសាស្ត្រសំរាប់ការពារសំខាន់នៅពេលនេះ គឺចង់បានការបង្កើតក្រុមសហការ ដោយមានព្រះសង្ឃចូលរួម ព្រមទាំងបង្កើតបណ្តាញការងារ ដើម្បីជួយសហការជាមួយអង្គការក្រៅរដ្ឋាភិបាល-ជាមួយក្រុមពលរដ្ឋស៊ីវិល និងក្រុមប៉ូលីសសហការផងដែរ ដែលក្រុមទាំងនេះកំពុងតែមានដំណើរការក្នុងការជួយទប់ស្កាត់ កាត់បន្ថយ និង លុបបំបាត់អំពើរំលោភសិទ្ធិមនុស្សជាច្រើនប្រភេទដែល កំពុងតែកើតមាន ។

## ១-ការជ្រើសរើសតំណាងក្រុម

ធ្វើការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ ដោយធ្វើការជ្រើសរើសប្រធានក្រុមមួយរូប និង អនុប្រធានក្រុមមួយរូប ( អ្នកបានសម្លេងគាំទ្រច្រើនជា ប្រធាន និងអ្នកបានសម្លេងគាំទ្របន្ទាប់ជាអនុប្រធាន ) ។

ក្រុមការងារនេះនឹងមានតម្លៃចាប់ពីពេលបង្កើតនេះតទៅ ដោយមានកិច្ចសហការជាមួយអង្គការលីកាដូ ជាមួយក្រុមប្រជាពលរដ្ឋស៊ីវិល និងជាមួយក្រុមប៉ូលីសសហការ (ជាក្រុមដែលលីកាដូបានរៀបចំរួចហើយ) ថាតើក្រុមនេះ ប្រធានមានតួនាទីធ្វើអ្វីខ្លះ អនុប្រធានធ្វើអ្វី និងសមាជិកធ្វើអ្វីទាក់ទងទៅនឹងការជួយកែប្រែស្ថានភាពសិទ្ធិមនុស្ស ឱ្យកាន់តែប្រសើរឡើង ។ ជាពិសេស ដើម្បីជួយផ្តល់ពត៌មានទាំងឡាយអំពីករណីរំលោភសិទ្ធិមនុស្ស ដែលបានកើតឡើងនៅក្នុង សហគមន៍ ។

ចំពោះក្រុមការងារនេះ អង្គការលីកាដូនឹងទំនាក់ទំនងរៀងរាល់ពីរខែម្តងដោយនិមន្តព្រះសង្ឃទាំងអស់ក្នុងវត្តនេះ មកជួបជុំរយៈពេលមួយថ្ងៃ ដើម្បីពិភាក្សាការងារដែលទាក់ទងទៅនឹងបញ្ហាសិទ្ធិមនុស្ស ថាតើបន្ទាប់ពីវត្តនេះទៅ ក្រុមសហការមានសកម្មភាពធ្វើអ្វីខ្លះ ក្នុងការជួយដល់សហគមន៍ ។

**២-ស្រង់ចំនួនករណីរំលោភសិទ្ធិមនុស្ស**

តើករណីអ្វីដែលបាននិងកំពុងកើតឡើងនៅក្នុង ភូមិ ឃុំ ស្រុករបស់ ព្រះអង្គ ? តើព្រះអង្គនឹងមានវិធីបែបណាដែលអាចជួយដោះស្រាយ ទៅបាន (ទុកជាគំរូ) ថាតើគួរត្រូវបានដោះស្រាយដូចម្ដេចរបៀបណា និងកិរិតណា ។

**ការពិភាក្សារបស់ក្រុមនីមួយៗតីរកចំណុចជាយុទ្ធសាស្ត្រសំរាប់ការពារ**

បើមានករណីអ្វីមួយកើតឡើង ត្រូវមានវិធីដូចម្ដេចខ្លះ ដែលជាយុទ្ធសាស្ត្រសំរាប់ការពារនោះ ?

-នៅក្នុងសហគមន៍នីមួយៗ ការរំលោភដែលត្រូវចាប់អារម្មណ៍ ហើយដែលគួរតែមានវិធានការជួយឈឺឆ្អាលនោះគឺមានដូចជា : អំពើហិង្សាក្នុងគ្រួសារ , ការចាប់និងការឃុំខ្លួនខុសច្បាប់ , ការធ្វើទារុណកម្មទៅលើជនដែលគេចាប់ខ្លួននិងឃុំខ្លួន , អំពើឃាតកម្ម (ការសម្លាប់មនុស្សដោយលួចលាក់និងចំហរ), ការគំរាមកំហែងទៅលើអ្នកនយោបាយ , ការចាប់ជំរិត , ការរំលោភលើដីធ្លីពីអាជ្ញាធរដោយផ្ទាល់ ដោយប្រយោល ដូចជាការសមគំនិតពីពួកសមត្ថកិច្ច មានទាហាន ប៉ូលីសប៉េអឹម និងតុលាការជាដើម ។ ក្នុងចំណោមករណីទាំងនេះ ប្រសិនបើមាន ក្រុមសហការអាចដោះស្រាយតាមលទ្ធភាពដែលអាចធ្វើទៅបាន យ៉ាងហោចណាស់ក៏ត្រូវផ្ដល់ពត៌មានដល់អង្គការសិទ្ធិមនុស្ស មានអង្គការលីកាដូជាដើមឱ្យបានឆាប់ដែលអាចធ្វើទៅបាន ឬនៅពេលវគ្គបន្ត បើសិនជាករណីរំលោភនោះមិនសូវមានសភាពធ្ងន់ធ្ងរ ។

## តារាងប្រភេទករណីរំលោភសិទ្ធិមនុស្ស

| ល.រ | ឈ្មោះករណីរំលោភ | កាលបរិច្ឆេទ | ទីកន្លែង(ភូមិ,ឃុំ,ស្រុក) | វិធីសំរបសំរួល |
|---|---|---|---|---|
| ១ | .......... | ......... | ......... | ........ |

| | | | | |
|---|---|---|---|---|
| ២ | .......... | | | |

-ត្រូវមានតារាងខាងលើពីរសន្លឹក បន្ទាប់ពីអ្នកចូលរួមពិភាក្សារកឃើញវិធីសំរបសំរួល ដោះស្រាយ អំពីករណីណាមួយដែលបានចុះក្នុងតារាងរួចហើយ ។ ប្រធានក្រុមទុកមួយសន្លឹកហើយផ្តាំសុំឱ្យយក មកវិញនៅពេលវគ្គបន្ត ។ ជាមួយគ្នានេះដែរផ្តល់តារាងថ្មី ថាតើបន្ទាប់ពីវគ្គនេះទៅ ក្រុមសហការ នេះនឹងបានជួយសំរបសំរួលឬដោះស្រាយ បានករណីអ្វីទៀត ធ្វើរបៀបណា ។ល។

**៣-សិក្សាទម្រង់រាយការណ៍សង្ខេប**

បើសិនជាករណីរំលោភមានលក្ខណៈធ្ងន់ធ្ងរ ករណីទាំងនោះគួរតែស្វែងរកពតិមានពិត គួរឱ្យទុក ចិត្តបាន ហើយទម្រង់បែបបទដែលត្រូវរាយពតិមាន មានដូចតទៅ :

## ទម្រង់របាយការណ៍សង្ខេប

**១.ឈ្មោះករណីរំលោភ :** ............................................................

**២.ជនរងគ្រោះ :**

ឈ្មោះ..........................ភេទ........អាយុ.............មុខរបរ......................................

ទីលំនៅៈភូមិ.......................ឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ........................

ខេត្ត/ក្រុង..................

ទីកន្លែងកើតហេតុៈភូមិ........................ឃុំ/សង្កាត់............................ស្រុក/ខណ្ឌ.......

.............................ខេត្ត/ក្រុង................................................

ពេលវេលា ៈម៉ោង...............ថ្ងៃទី..............ខែ..............ឆ្នាំ២០០...

**៣.អ្នកប្រព្រឹត្ត :**

ឈ្មោះ........................ភេទ...........អាយុ..............មុខរបរ.................................

ទីលំនៅ : ភូមិ......................ឃុំ..........................ស្រុក...................ខេត្ត..............

ពេលវេលា : ម៉ោង..............ថ្ងៃទី...............ខែ..............ឆ្នាំ ២០០....

**៤-ឧបករណ៍ដែលបានប្រើទៅលើជនរងគ្រោះ**

..........................................................................................................................

..........................................................................................................................

**៥-មូលហេតុដែលបណ្តាលឱ្យកើតរឿងនេះ :**

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

ធ្វើនៅថ្ងៃទី ខែ ឆ្នាំ ២០០....

អ្នករាយការណ៍

ហត្ថលេខា ...............

ឈ្មោះ....................

## II. ច្បាប់របស់ប្រទេសកម្ពុជា

**១-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

**<u>មាត្រា៣២</u>** : ជនរាល់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

**<u>មាត្រា៤២</u>** : ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។ ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផលជាតិនិងសណ្តាប់ធ្នាប់សង្គម ។

**២-ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាសម័យអន្តរកាល**

**<u>មាត្រា៣២</u>** : ជនណាដែលសម្លាប់មនុស្សដោយចេតនា ដោយបានប្រើឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោស ពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោស ដាក់ជាបទឧក្រិដ្ឋ ពី៨ឆ្នាំទៅ១៥ឆ្នាំ ។

**<u>មាត្រា៣៣</u>** : ជនណាក៏ដោយ ដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនណាម្នាក់ទៀត ទោះភេទដូចគ្នាឬមិនដូចគ្នាយ៉ាងណាក៏ដោយ ត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋពី ៥ ឆ្នាំទៅ១០ឆ្នាំ ។



***(ការសម្លាប់ដោយហ្វូងមនុស្ស)***

**<u>មាត្រា៣៤</u> : (អំពើប្លន់)** ការលួច ធ្វើដោយអំពើហិង្សា មានអាវុធឬឥតអាវុធ បណ្តាលឬមិនបណ្តាលឱ្យមានរបួស ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវមានទោសដាក់គុកពី៣ឆ្នាំ ទៅ ១០ឆ្នាំ ។

**<u>មាត្រា៤០</u> : ( អំពើមនុស្សឃាតដោយអចេតនា )** ជនណាដោយខ្វះការប្រុងប្រយ័ត្ន ដោយការធ្វេសប្រហែសដោយមិនប្រយ័ត្ន ឬ មិនបានគោរពតាមបទបញ្ជាធ្វើឱ្យស្លាប់ជនម្នាក់ទៀតដោយអចេតនា ត្រូវមានទោសពីបទមជ្ឈិមធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំទៅ៣ឆ្នាំ ។

**មាត្រា៤១** : (អំពើបង្ករបួសដោយចេតនា) ជនណាវាយតប់ បណ្តាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ឬពិការបណ្តោះអាសន្នក្នុងរយៈពេលលើសពី៦ខែដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំទៅ៥ឆ្នាំ ។

-បើពិការភាពបណ្តោះអាសន្នតិចជាង៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះពី៦ខែដល់២ឆ្នាំ ។

-បើគ្មានពិការភាពទេ ទោសដែលត្រូវកំនត់ផ្តន្ទា គឺដាក់គុកពី១ខែដល់១ឆ្នាំ ។

-បើការវាយតប់នោះធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កំរិតទោសត្រូវទ្វេមួយជាពីរ ។

**៣-ច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជំរិត អំពើជួញដូរនិងអំពើអាជីវកម្មលើមនុស្ស :**

**មាត្រា៣** : ជនណាអូសទាញមនុស្ស ទោះស្រីឬប្រុស អនីតិជនឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោម សន្យាឱ្យប្រាក់កាស ឬគ្រឿងអលង្ការ ឬតាមវិធីណាក៏ដោយ ទោះសាមីខ្លួនសុខចិត្តឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំគំរាមកំហែង ឬ វិធីណាក៏ដោយ ទោះសាមីខ្លួនសុខចិត្តឬមិនសុខចិត្ត ឬប្រើថ្នាំសណ្តំស្មារតីនិងសតិអារម្មណ៍ដើម្បីពង្រត់យកមកលក់ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំដល់១៥ឆ្នាំ ។

**ចប់**

# តារាងប្រភេទករណីរំលោភ

| ល.រ | ឈ្មោះករណីរំលោភ | កាលបរិច្ឆេទ | ទីកន្លែង(ភូមិ,ឃុំ,ស្រុក) | វិធីសំរបសំរួល |
|---|---|---|---|---|
| ១- | ........................... | ................................. | ................................. | ................... |
| ២ | ........................... | ................... | | |
| ៣ | ..................... | ............................ | | |
| ៤ | ....................... | ......................... | | |
| ៥ | ........................... | | | |

## ទម្រង់របាយការណ៍សង្ខេប

**១.ឈ្មោះករណីរំលោភ :** ..............................................................................

**២.ជនរងគ្រោះ :**

ឈ្មោះ.............................ភេទ........អាយុ.............មុខរបរ.......................................

ទីលំនៅ:ភូមិ.......................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ.......................

ខេត្ត/ក្រុង..................

ទីកន្លែងកើតហេតុ:ភូមិ........................ឃុំ/សង្កាត់...........................ស្រុក/ខណ្ឌ.......

.............................ខេត្ត/ក្រុង...............................................

ពេលវេលា :ម៉ោង...............ថ្ងៃទី..............ខែ..............ឆ្នាំ២០០...

**៣.អ្នកប្រព្រឹត្ត :**

ឈ្មោះ.........................ភេទ...........អាយុ..............មុខរបរ.................................

ទីលំនៅ : ភូមិ......................ឃុំ..........................ស្រុក..................ខេត្ត.............

ពេលវេលា : ម៉ោង..............ថ្ងៃទី..............ខែ..............ឆ្នាំ ២០០....

**៤-ឧបករណ៍ដែលបានប្រើទៅលើជនរងគ្រោះ**

..............................................................................................................

..............................................................................................................

**៥-មូលហេតុដែលបណ្ដាលឱ្យកើតរឿងនេះ :**

..............................................................................................................

..............................................................................................................

..............................................................................................................

ធ្វើនៅថ្ងៃទី ខែ ឆ្នាំ ២០០....

អ្នករាយការណ៍

ហត្ថលេខា ...............

ឈ្មោះ.....................

បោះពុម្ពផ្សាយដោយ
សម្ព័ន្ធខ្មែរជំរឿន និង ការពារ
សិទ្ធិមនុស្ស
Published by the Cambodian
League for the Promotion and
Defense of Human Rights

ឧបត្ថម្ភដោយថវិការបស់ ណូរ៉ាដ
Published with a grant from
**NORAD**

# ហាមលក់
# NOT FOR SALE

រក្សាសិទ្ធិដោយអង្គការ **លីកាដូ**
Copyright by LICADHO

បោះពុម្ពលើកទី១ ចំនួន ១០០០ ក្បាល
ខែ មករា ឆ្នាំ ២០០៣